ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិស្ដីពីដំឡូងមី

# ២០២០ - ២០២៥

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០

**រៀបចំ និងបោះពុម្ពដោយៈ**

ក្រសួងពាណិជ្ជកម្ម

អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម

នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម

**ឧបត្ថម្ភគាំទ្រការបោះពុម្ពដោយៈ**

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិស្តីពីដំឡូងមី
# ២០២០-២០២៥

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

## អារម្ភកថា

ក្នុងយុគសម័យសន្តិភាពពេញបរិបូរ កម្ពុជាបានសម្រេចជោគជ័យក្នុងការប្រែក្លាយពីប្រទេសដែលមានចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ ការសម្រេចកំណើនសេដ្ឋកិច្ចខ្ពស់ហើយថេរក្នុងរយៈពេលច្រើនទសវត្សនេះបានកាត់បន្ថយភាពក្រីក្រឱ្យធ្លាក់ចុះទាបមកនៅត្រឹម១០ភាគរយនៅឆ្នាំ២០១៨ និងពង្រីកទំហំសេដ្ឋកិច្ចកាន់តែធំថែមទៀត។ កម្ពុជាក៏បានផ្សារភ្ជាប់ជាមួយខ្សែច្រវាក់តម្លៃសកលនៃផលិតផលជាច្រើនមុខនិងកំពុងបង្កើនសក្តានុពលរបស់ខ្លួន ដើម្បីក្លាយជាមជ្ឈមណ្ឌលតំបន់លើផលិតផលនិងសេវាមួយចំនួនដែលខ្លួនមានឧត្តមភាពប្រកួតប្រជែងនិងកាលានុវត្តភាព។

ស្របតាមការរីកចម្រើនឥតឈប់ឈរនិងចក្ខុវិស័យអភិវឌ្ឍរយៈពេលវែង ជាពិសេសគឺការសម្រេចគោលដៅក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ គោលនយោបាយនេះបានកំណត់យកការធ្វើពិពិធកម្មមូលដ្ឋានគ្រឹះសេដ្ឋកិច្ច ដោយបង្កើតឱ្យមានសកម្មភាពពាណិជ្ជកម្មថ្មីៗ ស្របពេលនឹងការធ្វើពិពិធកម្មនៅក្នុងវិស័យដែលសកម្មរួចជាស្រេច។ ក្នុងចំណោមវិស័យស្នូលទាំងអស់ដែលមាន វិស័យកសិកម្មនៅតែជាកម្លាំងចលករដ៏សំខាន់ក្នុងការទ្រទ្រង់សេដ្ឋកិច្ចជាតិនិងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។ គ្រួសារជាច្រើន ប្រមាណ៣៧ភាគរយនៃកម្លាំងពលកម្មសរុបដែលមានក្នុងស្រុក កំពុងប្រកបរបរកសិកម្មនិងធ្វើការងារស្រែចម្ការបន្តពីមួយទៅមួយឥតដាច់ជាលំដាប់តាមប្រតិទិនរដូវដែលរួមមាន ការដាំដុះ កែច្នៃដឹកជញ្ជូន និងនាំចេញកសិផល។

ដោយមើលឃើញពីការរីកចម្រើននៃវិស័យកសិ-ពាណិជ្ជកម្មនិងជីវភាពគ្រួសារកសិករ ជាពិសេសការបង្កើតក៏ដូចជាការផ្តល់ឱកាសការងារដល់ប្រជាពលរដ្ឋនៅជនបទដោយផ្ទាល់ រាជរដ្ឋាភិបាលកម្ពុជាសម្រេចដាក់ចេញវិធានការគាំទ្រវិស័យនេះ ដោយផ្អែកលើអភិក្រមមួយដែលឆ្លើយតបតាមតម្រូវការទីផ្សារ រចនាសម្ព័ន្ធខ្សែច្រវាក់តម្លៃសកលនិងប្រព័ន្ធនៃផលិតកម្មដំណាំត្រូវច្របាច់បញ្ចូលគ្នាក្នុងគោលនយោបាយនិងផែនការសកម្មភាពរួមមួយ។ ក្នុងស្ថានភាពបច្ចុប្បន្ននិងតទៅអនាគត ដំណាំដំឡូងមីដែលជាដំណាំធំទីពីរបន្ទាប់ពីស្រូវ ត្រូវមានការគាំទ្រពិសេសដើម្បីទាញយកប្រយោជន៍ឱ្យបានជាអតិបរមានិងការអភិវឌ្ឍដំណាំនេះឱ្យក្លាយជាកម្លាំងចលករដ៏ខ្លាំងក្លាមួយក្នុងការធ្វើបរិវត្តន៍កសិ-ឧស្សាហកម្មនៅកម្ពុជា ដែលទិសដៅនេះបានកំណត់យ៉ាងជាក់ច្បាស់ក្នុងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥។ ការបង្កើនសមត្ថភាពកែច្នៃផលិតផលសម្រេចចេញពីដំឡូងមី ដើម្បីជំរុញការនាំចេញពីកម្ពុជាដោយផ្ទាល់ទៅកាន់ទីផ្សារពិភពលោក ដោយនាំត្រឡប់មកវិញនូវរូបិយបណ្ណអន្តរជាតិ ព្រមទាំងជំរុញឱ្យមានការកសាងបណ្តាញតភ្ជាប់ជាមួយអនុវិស័យកសិកម្មនិងឧស្សាហកម្មក្នុងស្រុកផ្សេងៗជាច្រើនទៀត ដែលបង្កើតបាននូវប្រព័ន្ធសេដ្ឋកិច្ចប្រទាក់ក្រឡាដ៏រស់រវើក។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមអបអរសាទរនិងកោតសរសើរចំពោះក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងក្រសួងពាក់ព័ន្ធដទៃ

ទៀត វិទ្យាស្ថានស្រាវជ្រាវ សាកលវិទ្យាល័យ ដៃគូអភិវឌ្ឍ វិស័យឯកជន រោងចក្រកែច្នៃ កសិករ និងប្រតិបត្តិករទាំងអស់ដែលបានចូលរួមក្នុងការរៀបចំគោលនយោបាយជាតិជំឡូងមីនេះ។ ការផ្ដល់វិភាគទានដូចជា ថវិកា ចំណេះដឹង បច្ចេកទេស បទពិសោធ ព័ត៌មាន ស្មារតីទទួលខុសត្រូវ និងឆន្ទៈបំពេញការងារ គឺជាធនធានដែលមិនអាចខ្វះបាននៅក្នុងការរៀបចំគោលនយោបាយ ដែលដំណាក់កាលទីមួយនេះបានសម្រេចរួចរាល់ជាស្ថាពរ។ សម្រាប់ដំណាក់កាលបន្ទាប់ទៀត គឺការអនុវត្តគោលនយោបាយនិងការវាយតម្លៃលើផលប៉ះពាល់កើតចេញពីការអភិវឌ្ឍនេះ។

ឈរលើមូលដ្ឋាននៃបទពិសោធជោគជ័យនិងមេរៀនដែលទទួលបានពីគោលនយោបាយស្ដីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ខ្ញុំជឿជាក់ថា កម្ពុជានឹងធ្វើឱ្យពិភពលោកមានសេចក្ដីសោមនស្សរីករាយជាថ្មីម្ដងទៀត ជាមួយនឹងតួនាទីរបស់ខ្លួនជាអ្នកផ្គត់ផ្គង់ស្បៀងអាហារនិងជាតុចូលឧស្សាហកម្ម (ម្សៅជំឡូងមី) នៅក្នុងខ្សែច្រវាក់តម្លៃសកល។ ខ្ញុំមានសុទិដ្ឋិនិយមថា ការសម្រេចលទ្ធផលនៃគោលនយោបាយនេះនឹងនាំមកនូវវិបុលភាពដល់សេដ្ឋកិច្ចមូលដ្ឋាន ពង្រីកមូលដ្ឋានគ្រឹះសេដ្ឋកិច្ចជាតិកាន់តែធំទូលាយ និងផ្ដល់ជីវភាពធូរធារសម្បូរសប្បាយដល់ប្រជាពលរដ្ឋ តាមរយៈការកសាងបាននូវប្រព័ន្ធផលិតកម្មជំឡូងមីប្រកបដោយនិរន្តរភាពនិងការកកើតរោងចក្រកែច្នៃផលិតផលដ៏ច្រើនសម្បូរបែបនៅកម្ពុជា។ ដោយសារតែគោលនយោបាយជាតិជំឡូងមីនេះ ជាចំណែកដ៏សំខាន់មួយក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបួននិងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣) ខ្ញុំសូមលើកទឹកចិត្តនិងជំរុញគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ឱ្យគាំទ្រនិងចូលរួមអនុវត្តគោលនយោបាយនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃពុធ ១៥កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ២០២០

**ហ៊ុន សែន**

## មាតិកា


**អារម្ភកថា** .................................................... i

**១. សេចក្តីផ្តើម** .................................................... ១

**២. ចក្ខុវិស័យ** .................................................... ៦

**៣. គោលបំណងនិងគោលដៅ** .................................................... ៦

**៤. យុទ្ធសាស្ត្រដើម្បីសម្រេចគោលនយោបាយ** .................................................... ៦

**៥. ផែនការសកម្មភាព** .................................................... ៨

៥.១. ការបង្កើតយន្តការ .................................................... ៨

៥.២. ការបង្កើតក្របខ័ណ្ឌគតិយុត្ត .................................................... ៨

៥.៣. ការគាំទ្រហិរញ្ញវត្ថុ .................................................... ៩

៥.៤. ការបណ្តុះបណ្តាលធនធានមនុស្ស .................................................... ៩

៥.៥. ហេដ្ឋារចនាសម្ព័ន្ធ .................................................... ៩

៥.៦. ដំណើរការអនុវត្តគម្រោង .................................................... ៩

៥.៦.១. គម្រោងរយៈពេលប្រាំឆ្នាំ .................................................... ១០

៥.៦.២. គម្រោងរយៈពេល១០ឆ្នាំ .................................................... ១៥

៥.៧. ការគ្រប់គ្រងហានិភ័យ .................................................... ១៦

**៦. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** .................................................... ១៨

**៧. សេចក្តីសន្និដ្ឋាន** .................................................... ១៩

**សន្ទានុក្រម** .................................................... ២០

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទី១៖ សកម្មភាពលម្អិតសម្រាប់អនុវត្តគោលនយោបាយជាតិដំឡូងមី

ឧបសម្ព័ន្ធទី២៖ តារាងទិន្នន័យ

តារាងទី១ : ផលិតផលសក្តានុពលនិងទីផ្សារប្រទេសគោលដៅសម្រាប់ផលិតផលដំឡូងមីកម្ពុជា

តារាងទី២ : ការនាំចូលម្សៅមីក្នុងពិភពលោក "មិនទាន់កែច្នៃ" HS-110814

តារាងទី៣ : ការនាំចូលម្សៅមី "កែច្នៃ" របស់ប្រទេសនានាលើពិភពលោក HS-350510

តារាងទី៤ : ការព្យាករទីផ្សារម្សៅមីពិភពលោកសម្រាប់ឆ្នាំ២០២០-២០២៥

## ១. សេចក្ដីផ្ដើម

គោលនយោបាយនេះបានសម្រេចកំណើនសេដ្ឋកិច្ចដ៏រឹងមាំអស់រយៈពេលជាច្រើនឆ្នាំ ដែលបានធ្វើឱ្យកម្ពុជាទទួលបានកិត្តិនាមជាខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី[១]។ លទ្ធផលនៃកំណើនសេដ្ឋកិច្ចខ្ពស់នេះបានកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័សនិងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពរបស់ប្រជាជនកម្ពុជាជាច្រើនលាននាក់។ ភាពជោគជ័យដ៏ធំនេះកើតចេញពីសមត្ថភាពនិងកិច្ចខិតខំប្រឹងប្រែងដ៏ខ្លាំងក្លារបស់គោលនយោបាយនេះ ក្នុងការរក្សាសន្តិភាព ស្ថិរភាព និងសុខដុមនីយកម្មសង្គម ដែលជាមូលដ្ឋានគ្រឹះនៃកំណែទម្រង់រដ្ឋបាលសាធារណៈ ការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាពក្នុងការទាក់ទាញវិនិយោគ ការធ្វើសមាហរណកម្មដោយរលូនទៅក្នុងសេដ្ឋកិច្ចតំបន់និងពិភពលោក និងសេរីភាវូបនីយកម្មពាណិជ្ជកម្ម។ គោលនយោបាយទាំងនេះបានជំរុញការអភិវឌ្ឍវិស័យជាច្រើន ដូចជាវិស័យទេសចរណ៍ វិស័យកាត់ដេរ វិស័យសំណង់ វិស័យកសិកម្ម និងវិស័យថ្មីៗទៀត រួមមានវិស័យអចលនទ្រព្យនិងឧស្សាហកម្មកម្មន្តសាល។

ដើម្បីរក្សាកំណើនសេដ្ឋកិច្ចសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងធ្វើឱ្យកម្ពុជាក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់មួយដ៏រស់រវើកក្នុងប្រព័ន្ធសេដ្ឋកិច្ចតំបន់និងពិភពលោក គោលនយោបាយនេះប្ដេជ្ញាយ៉ាងមុតមាំក្នុងការពង្រីកនិងធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួនឱ្យកាន់តែធំនិងសម្បូរបែប ដោយផ្ដោតលើវិស័យដែលមានសក្ដានុពលក្នុងការលើកកម្ពស់ជីវភាពប្រជាជន ផ្ដល់ឧត្តមប្រយោជន៍ដល់សង្គមជាតិ និងមានឧត្តមភាពប្រកួតប្រជែងពាណិជ្ជកម្ម។ ជម្រើសមួយសម្រាប់ការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចនេះ គឺការអភិវឌ្ឍខ្សែច្រវាក់តម្លៃកសិកម្មថ្មីៗដែលមានលក្ខណៈសកម្មនិងថាមវន្ត ហើយមានការចូលរួមច្រើនកុះករពីប្រជាកសិករ ពលករ ពាណិជ្ជករ និងប្រតិបត្តិករផ្សេងៗ។ គោលនយោបាយនេះចាត់ទុកថា ការធ្វើទំនើបកម្មកសិកម្មជាជម្រើសអាទិភាពដ៏សំខាន់ចាំបាច់បំផុតមួយ ជាពិសេសគឺការផ្លាស់ប្ដូរពីកសិកម្មបែបប្រពៃណី ផលិតកម្មគ្រួសារមិនស្របតាមបទដ្ឋានបច្ចេកទេសនិងតាមយថាផល ទៅជាកសិ-ពាណិជ្ជកម្មដែលមានភាពសុក្រឹតនៃផលិតកម្មអាចព្យាករនិងគ្រប់គ្រងបាន។ ការអភិវឌ្ឍនេះនឹងបង្កើតបានខឿនកសិ-ឧស្សាហកម្មបន្ថែមសម្រាប់ជាតិ ដែលបង្កើតការងារថ្មីនិងអភិវឌ្ឍជំនាញវិជ្ជាជីវៈច្រើនបែបដល់ពលករនិងយុវជនកម្ពុជា។ ការធ្វើពាណិជ្ជូបនីយកម្មកសិកម្មនិងការអភិវឌ្ឍកសិ-ឧស្សាហកម្មអាចបង្កើនប្រាក់ចំណូលបន្ថែមដល់ប្រជាជននិងផ្សារភ្ជាប់វិស័យពាក់ព័ន្ធផ្សេងៗ ដែលបង្កើតបាននូវភាពប្រទាក់ក្រឡានៃចរន្តសេដ្ឋកិច្ចនិងបង្កើនឧត្តមភាពនៃការនាំចេញផលិតផលពីប្រទេសកម្ពុជាទៅកាន់ទីផ្សារពិភពលោក។

គោលនយោបាយនេះចាត់ទុកដំឡូងមីជាដំណាំសក្ដានុពលមួយក្នុងចំណោមដំណាំជាច្រើនផ្សេងទៀតសម្រាប់កសិករដែលមានធនធានតិចតួច និង/ឬកសិករខ្នាតតូច ដើម្បីកែលម្អជីវភាពរបស់ពួកគេ និងជាមូលដ្ឋានគ្រឹះមួយសម្រាប់ការអភិវឌ្ឍកសិ-ឧស្សាហកម្មនៅកម្ពុជា។ ទស្សនាទាននេះមានលក្ខណៈស្របគ្នាជាមួយនឹងពិភពលោកដែលកំពុងលើកស្ទួយដំឡូងមីជាមួយនឹងកិត្យានុភាពជាដំណាំប្រចាំសតវត្សទី២១ ឬជាស្បៀងអាហារសម្រាប់សតវត្សទី២១[២]។

[១] ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១៦ កម្ពុជានៅទីនេះសេដ្ឋកិច្ចខ្លាថ្មីរបស់អាស៊ី(១០ ឧសភា ២០១៦) https://www.adb.org/news/features/here-comes-cambodia-asia-s-new-tiger-economy

[២] អង្គការ ស្បៀងអាហារពិភពលោក ឆ្នាំ២០១៣ ជួយសង្គ្រោះ ការដាំដុះដំឡូងមី ឯកទេសណែនាំ ស្ដីពីផលិតផលខ្មែរបែបនិរន្តរភាព។

ជាច្រើនទសវត្សមកនេះ គោលនយោបាយនេះបានមើលឃើញពីភាពរីកចម្រើនដូចខាងក្រោម៖

**ការរីកលូតលាស់នៃផលិតកម្មដំឡូងមី** : ការរីកចម្រើនយ៉ាងឆាប់រហ័សនៃតំបន់ដាំដុះដំឡូងមីក្នុងទសវត្សចុងក្រោយនេះបានធ្វើឱ្យដំណាំដំឡូងមី ក្លាយជាដំណាំសំខាន់ទីពីរ បន្ទាប់ពីស្រូវនៅកម្ពុជា។ ដំឡូងមីមានចំណែកចន្លោះពី៣ទៅ៤ភាគរយនៃផលិតផលសរុបក្នុងស្រុក[៣]។ ក្នុងមួយឆ្នាំៗ ថវិកាប្រហែល៣០០លានដុល្លារអាម៉េរិកត្រូវបានវិនិយោគដើម្បីដាំដុះដំឡូងមីលើផ្ទៃដីទំហំធំជាង៦០០ ០០០ហិកតា។ ខណៈដែលការនាំចេញភាគច្រើនជាមើមដំឡូងមីស្រស់និងចំណិតដំឡូងមីក្រៀមមានតម្លៃប្រហែល៧២៨លានដុល្លារអាម៉េរិក[៤]។ ប្រជាជននៅជនបទច្រើនជាង៩០ ០០០(ប្រាំបួនម៉ឺន)គ្រួសាររស់នៅក្នុងខេត្តចំនួន១៣ កំពុងប្រកបរបរដាំដុះដំឡូងមីនិងពលករជាច្រើនកំពុងបម្រើការក្នុងវិស័យនេះ ក្នុងដំណាក់កាលផ្សេងៗ ដូចជា ដាំដុះ ប្រមូលផល កែច្នៃ និងនាំចេញ។ កន្លែងប្រមូលទិញផលិតផលដំឡូងមីមានចំនួន៥៥០កន្លែង ភាគច្រើនស្ថិតនៅក្នុងខេត្តចំនួនប្រាំ ដូចជា ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តត្បូងឃ្មុំ។ ខេត្តទាំងនេះមានផ្លូវតភ្ជាប់ដោយផ្ទាល់សម្រាប់ការនាំចេញដំឡូងមីពីចម្ការនៅកម្ពុជា ទៅកាន់រោងចក្រកែច្នៃ ឃ្លាំងស្តុកទុក និងកំពង់ផែរបស់ប្រទេសជិតខាង។ បន្ថែមលើនេះ ក្នុងចំណោមរោងចក្រកែច្នៃម្សៅដំឡូងមីក្នុងស្រុកទាំងខ្នាតតូចនិងខ្នាតធំចំនួន១៧ មានរោងចក្រចំនួន១៤ដែលនៅដំណើរការគិតត្រឹមឆ្នាំ២០១៨។ គួរកត់សម្គាល់ថា មានរោងចក្រកែច្នៃម្សៅថ្មីៗមួយចំនួន ទៀតកំពុងដំណើរការសាងសង់។ រោងចក្រចម្រាញ់អេតាណុលពីដំឡូងមីចំនួន៧បានដំណើរការអស់រយៈពេលជាច្រើនឆ្នាំមកហើយ។

**ការកកើតឡើងនៃផលិតកម្មដំឡូងមីនៅកម្ពុជា** : ការកើនឡើងតម្រូវការចំណិតដំឡូងមីក្រៀមសម្រាប់ចម្រាញ់អេតាណុលនិងម្សៅរបស់ប្រទេសចិន បានបង្កើតប្រព័ន្ធពាណិជ្ជកម្មដ៏សកម្មមួយរវាងអាស៊ីបូព៌ានិងអាស៊ីអាគ្នេយ៍។ ក្នុងប្រព័ន្ធពាណិជ្ជកម្មនេះអាចកំណត់បានថា ប្រទេសចិនជាអ្នកបញ្ជាទិញធំជាងគេនៅក្នុងពិភពលោក ហើយប្រទេសថៃនិងវៀតណាមជាអ្នកផ្គត់ផ្គង់ដ៏ធំបំផុតសម្រាប់ទីផ្សារចិននិងទីផ្សារអន្តរជាតិ ខណៈពេលដែលកម្ពុជាដើរតួនាទីជាអ្នកដាំដុះដំឡូងមី។ ប្រទេសជិតខាងយើងមិនអាចពង្រីកផ្ទៃដីដាំដុះដំឡូងមីរបស់ខ្លួនបានដោយសារផ្ទៃដីដាំដុះដំណាំកសិកម្មរបស់ពួកគេត្រូវបានកំណត់និងបែងចែកច្បាស់លាស់។ រដ្ឋាភិបាលនៃប្រទេសទាំងនេះបានកំណត់ឱ្យដាំដុះដំណាំដំឡូងមីនៅលើដីដែលមានជីជាតិតិចនិងគ្មានប្រព័ន្ធធារាសាស្ត្រ។ ហេតុនេះហើយបានជាប្រទេសទាំងនេះបង្កើតទីផ្សារដំឡូងមីនិងប្រព័ន្ធគាំទ្រផលិតកម្មដោយប្រយោលសម្រាប់ប្រទេសកម្ពុជា តាមរយៈការផ្គត់ផ្គង់ធាតុចូលកសិកម្ម ដើមដំឡូងមី ការចែករំលែកចំណេះដឹងក្សេត្រសាស្ត្រតាមបណ្តាញក្រៅផ្លូវការដល់កសិករនិងកសាងកន្លែងប្រមូលទិញដំឡូងមីស្រស់និងចំណិតដំឡូងមីក្រៀម។ ជាលទ្ធផល ដំណាំដំឡូងមីត្រូវបានដាំដុះភាគច្រើននៅតំបន់តាមព្រំដែននិងរីករាលដាលមកតំបន់ភាគខាងក្នុងប្រទេស ដូចជាការដាំដុះនៅក្នុងចម្ការស្វាយចន្ទី កៅស៊ូ និង/ឬដីលាត។

**រចនាសម្ព័ន្ធខ្សែច្រវាក់តម្លៃដំឡូងមីក្នុងតំបន់** : ទីផ្សារដំឡូងមីនៅអាស៊ីបានបង្កើតខ្សែច្រវាក់តម្លៃតំបន់មួយដែលប្រទេសកម្ពុជាជាអ្នកដាំដុះ ប្រមូលផល និងកែច្នៃបឋម ខណៈពេលដែលប្រទេសជិតខាងដែលគ្រប់គ្រងទីផ្សារនិងមានឧត្តមភាពប្រកួតប្រជែងផ្នែកពាណិជ្ជកម្មដើរតួនាទីជាអ្នកកែច្នៃ នាំចេញ និងចរចាតម្លៃ។ ទោះបីជាទំហំផលិតកម្មដំឡូងមីស្ថិតនៅលំដាប់ទីបួនក្នុងតំបន់និងលំដាប់ទីប្រាំបីនៅលើពិភពលោកក៏ដោយ ក៏ប្រទេសកម្ពុជាមិន

[៣] កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ឆ្នាំ២០១៦ ការសិក្សាស្តីពីខ្សែច្រវាក់តម្លៃដំឡូងមីរបស់កម្ពុជា

[៤] របាយការណ៍វិភាគស្តីពីឧស្សាហកម្មដំឡូងមី(ឆ្នាំ២០១៧) , ASCS-Radius for its client, Green Leader Co. Ltd.

ត្រូវបានគេស្គាល់នៅក្នុងទីផ្សារ[៥]។ អស់រយៈពេលជាច្រើនឆ្នាំ កម្ពុជាបន្តតួនាទីរបស់ខ្លួនដោយបំពេញតម្រូវការទីផ្សារដោយប្រយោល ក្នុងនាមជាអ្នកផ្គត់ផ្គង់បំពេញបន្ថែម( Marginal Supplier ) និងជាអ្នកទទួលយកថ្លៃដែលកំណត់ដោយទីផ្សារ( Price taker )។

ដំឡូងមី គឺជាដំណាំកសិ-ពាណិជ្ជកម្មសម្រាប់ការនាំចេញនិងមិនមែនជាអាហារមូលដ្ឋានសម្រាប់ចិញ្ចឹមជីវិតរបស់ប្រជាជនកម្ពុជាឡើយ ប៉ុន្តែវាជាអាហារដ៏សំខាន់មួយរបស់ប្រជាជនឥណ្ឌូណេស៊ី ឥណ្ឌា អាហ្វ្រិក និងអាម៉េរិកឡាទីនមួយចំនួនធំ។ នៅកម្ពុជា ដំឡូងមីត្រូវបានគេប្រើប្រាស់សម្រាប់អាហារនិងចំណីសត្វតិចតួច ហើយត្រូវបាននាំចេញក្នុងទម្រង់ជាវត្ថុធាតុដើមស្ទើរតែទាំងស្រុងទៅកាន់ប្រទេសជិតខាង។ ភាគច្រើន ដំឡូងមីស្រស់ត្រូវបានកែច្នៃទៅជាម្សៅនៅប្រទេសជិតខាងនិងចំណិតដំឡូងមីក្រៀមសម្រាប់ចម្រាញ់អេតាណុលត្រូវបានទិញស្តុកទុកនៅប្រទេសជិតខាង។ បន្ថែមលើផលិតផលដំឡូងមីដែលខ្លួនមាន ប្រទេសជិតខាងទាំងពីរនេះបាននាំចេញផលិតផលដំឡូងមីកម្ពុជាទៅកាន់ប្រទេសចិននិងទីផ្សារផ្សេងៗទៀត។ ការនាំចេញដោយផ្ទាល់ពីកម្ពុជាទៅប្រទេសចិន មានទំហំតូចដែលមានតម្លៃត្រឹមតែ១៥.៥លានដុល្លារអាម៉េរិក ឬ៨១ ៤៩៧តោនសម្រាប់ចំណិតដំឡូងមីក្រៀម និង១០.៥លានដុល្លារអាម៉េរិក ឬ៣០ ៩៣៧តោនសម្រាប់ម្សៅមីនៅឆ្នាំ២០១៦[៦]។ រហូតមកទល់ពេលនេះ បរិមាណនៃការនាំចេញដោយផ្ទាល់ពីកម្ពុជាមិនទាន់មានការកើនឡើងគួរឱ្យកត់សម្គាល់នោះទេ។

**និន្នាការទីផ្សារដំឡូងមី** : ដំឡូងមីត្រូវបានគេដាំដុះក្នុងប្រទេសច្រើនជាង៩០នៅទ្វីបអាហ្វ្រិក អាម៉េរិកឡាទីន និងអាស៊ី។ វាគឺជាដំណាំសំខាន់បំផុតបន្ទាប់ពីស្រូវ ពោត និងស្រូវសាលី និងជាស្បៀងអាហាររបស់មនុស្ស ៧៧០លាននាក់។ ផលិតកម្មដំឡូងមីពិភពលោកបានកើនឡើង២.៥ភាគរយ រវាងឆ្នាំ២០០៩-២០១៦ ដែលបរិមាណផលផលិតបានឈានដល់២៨០លានតោនក្នុងឆ្នាំ២០១៦[៧]។

ក្នុងរយៈពេល២ឆ្នាំកន្លងមកនេះ ពាណិជ្ជកម្មដំឡូងមីពិភពលោកមានភាពអាក់រអួល ដោយសារការធ្លាក់ចុះតម្លៃកសិផលជំនួសដូចជា ពោតនិងស្រូវសាលី។ តម្លៃដំឡូងមីនិងកសិផលជំនួសមានលក្ខណៈខុសគ្នាតិចតួចដូច្នេះនាំឱ្យភាពប្រកួតប្រជែងរបស់ដំឡូងមីបានថយចុះ។ ឧស្សាហកម្មកែច្នៃជាច្រើនបានឆ្លើយតបនឹងបាតុភូតនេះដោយងាកទៅប្រើប្រាស់វត្ថុធាតុដើមជំនួសដែលមានតម្លៃថោកជាងដំឡូងមី។

ការផ្លាស់ប្តូរគោលនយោបាយកសិកម្មរបស់ប្រទេសចិនក៏ផ្តល់ផលប៉ះពាល់ដល់តម្លៃដំឡូងមី។ ការដកចេញនូវការឧបត្ថម្ភធនលើផលិតកម្មពោតនិងការបញ្ចេញស្តុកពោតនៅក្នុងប្រទេសចិនក្នុងរដូវដាំដុះនិងប្រមូលផលឆ្នាំ២០១៦/២០១៧ បណ្តាលឱ្យថ្លៃពោតធ្លាក់ចុះពី៣៦០ ទៅ២០០ដុល្លារអាម៉េរិកក្នុងមួយតោន។ កត្តាទាំងនេះបានជំរុញឱ្យថ្លៃដំឡូងមីនៅក្នុងតំបន់អាស៊ានធ្លាក់ចុះដល់កម្រិតទាប គឺ១៦០ដុល្លារអាម៉េរិកក្នុងមួយតោនសម្រាប់ចំណិតដំឡូងមីក្រៀម និង៣២០ដុល្លារអាម៉េរិកក្នុងមួយតោនសម្រាប់ម្សៅដំឡូងមី។ ក្រោយការធ្លាក់ចុះតម្លៃដ៏គំហុកនេះ តម្លៃដំឡូងមីបានកើនឡើងវិញពីកម្រិតទាបនៅឆ្នាំ២០១៦-២០១៧ ដល់កម្រិតខ្ពស់បំផុតគឺ២៤០ដុល្លារអាម៉េរិកក្នុងមួយតោនសម្រាប់ចំណិតដំឡូងមីក្រៀម និង៥៥០ដុល្លារអាម៉េរិកក្នុងមួយតោនសម្រាប់ម្សៅដំឡូងមីនៅឆ្នាំ២០១៧/២០១៨។ ថ្លៃខ្ពស់នេះមិនធ្លាប់មានពីមុនមកចាប់តាំងពីមានការរាតត្បាតចៃម្សៅ( mealybug ) ក្នុងឆ្នាំ ២០១០ នៅប្រទេសជិតខាង។ ការថយចុះបរិមាណផលដំឡូងមី គឺជាកត្តាចម្បងជំរុញឱ្យថ្លៃកើនឡើង ព្រោះ

[៥] ប្រព័ន្ធទិន្នន័យរបស់អង្គការស្បៀងអាហារពិភពលោក (៣០ តុលា ២០១៨) http://www.fao.org/faostat/en/#data/QC

[៦] ផែនទីពាណិជ្ជកម្ម ITC, ទិន្នន័យដកស្រង់ក្នុងខែមីនា ឆ្នាំ២០១៨

[៧] ទីផ្សារម្សៅដំឡូងមីរបស់ IMAR (2017) និន្នាការសកល ចែករំលែក ទំហំ កំណើន ឱកាស និងការព្យាករ ២០១៧-២៣, www.imarcgroup.com

ផលិតកម្មដំឡូងមីត្រូវបានខូចខាតដោយសារទឹកជំនន់នៅប្រទេសជិតខាង ការកាត់បន្ថយផ្ទៃដីដាំដុះដោយសារតម្លៃធ្លាក់ចុះក្នុងឆ្នាំកន្លងមក និងការកកើតជំងឺនៅប្រទេសជិតខាងនិងកម្ពុជា[៨]។

បើពិនិត្យមើលទីផ្សារដំឡូងមីជារួម ប្រទេសចិននៅតែជាអ្នកទិញធំជាងគេបំផុតនូវចំណិតដំឡូងមីក្រៀម និងម្សៅដំឡូងមីពីតំបន់អាស៊ីអាគ្នេយ៍ ដែលស្រូបយក៧៧ភាគរយនៃចំណែកទីផ្សារពិភពលោកនៅឆ្នាំ២០១៦។ ទោះបីជាប្រទេសចិនមានសមត្ថភាពផលិតពោតគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការរបស់ខ្លួនហើយក៏ដោយ ប្រទេសនេះនៅបន្តពឹងផ្អែកលើការផ្គត់ផ្គង់កសិផលពីបណ្តាប្រទេសផ្សេងៗទៀត ព្រោះថាដំណាំពោតងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុនិងដើម្បីធានាសន្តិសុខស្បៀងដល់ប្រជាជនរបស់ខ្លួន។ គួរឱ្យកត់សម្គាល់ផងដែរថា រដ្ឋាភិបាលចិនបានចេញសេចក្តីប្រកាសពីការអនុវត្តគោលនយោបាយប្រើប្រាស់ E10 (អេតាណុល១០ភាគរយលាយជាមួយនឹងប្រេងឥន្ធនៈ) នៅទូទាំងប្រទេសចិន ដែលនេះជាសញ្ញាមួយបង្ហាញថា វត្ថុធាតុដើមនិងសមត្ថភាពចម្រាញ់អេតាណុលត្រូវបង្កើនថែមទៀតដើម្បីសម្រេចគោលដៅនៃគោលនយោបាយនេះ[៩]។

ការផលិតម្សៅដំឡូងមីមានបរិមាណ៦លានតោន ជាមួយនឹងកំណើន២,២ភាគរយ ចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៦ តាមការចុះបញ្ជីអត្រាកំណើនប្រចាំឆ្នាំសរុប (Compound Annual Growth Rate CAGR) ហើយវាមានចំណែក៨ភាគរយនៃបរិមាណម្សៅសរុបរបស់ពិភពលោក ដែលផលិតចេញពីកសិផលផ្សេងៗទៀត។ តម្រូវការម្សៅដំឡូងមីពិភពលោកត្រូវបានគេរំពឹងថា នឹងកើនឡើងក្នុងកម្រិត CAGR ១.៩ភាគរយ ចន្លោះឆ្នាំ២០១៧និងឆ្នាំ២០២២ ដែលបរិមាណរបស់វានឹងកើនដល់៧.៤លានតោននៅឆ្នាំ២០២២[១០]។ យោងតាមការសិក្សា ម្សៅដំឡូងមីកំពុងត្រូវបានគេប្រើប្រាស់ក្នុងការផលិតទឹកស្ករសម្រាប់ភេសជ្ជៈនិងសារធាតុបន្ថែមក្នុងអាហារច្រើនមុខ។ ម្សៅដំឡូងមីក៏ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងឧស្សាហកម្មជាច្រើន ដូចជា ឱសថ ក្រដាស វាយនភណ្ឌ ក្តារបន្ទះ ថ្នាំលាប កាវ សំបកដប ថង់ប្លាស្ទិក ។ល។ សំណល់ពីម្សៅដំឡូងមីអាចផលិតជាចំណីសត្វ ជី និងជីវឧស្ម័ន។

អេតាណុលចម្រាញ់ចេញពីដំឡូងមីអាចជាផលិតផលសក្តានុពលមួយសម្រាប់ប្រទេសកម្ពុជា ប្រសិនបើមានការយកចិត្តទុកដាក់ពីអ្នកពាក់ព័ន្ធក្នុងខ្សែច្រវាក់តម្លៃនេះ។

ដើម្បីមាននិរន្តរភាព ដំឡូងមីគួរតែកែច្នៃជាផលិតផលសម្រេចច្រើនបែបសម្រាប់ទីផ្សារផ្សេងៗ ដូចនេះតម្លៃផលិតផលអាស្រ័យនឹងលទ្ធភាពទិញរបស់អតិថិជនក្នុងទីផ្សារនីមួយៗ។ ការផ្តោតទៅលើទីផ្សារក្នុងស្រុកជាជម្រើសមួយ ដោយសារតម្លៃកែច្នៃផលិតផលនៅនឹងកន្លែងអាចប្រកួតប្រជែងជាមួយនឹងផលិតផលនាំចូលពីបរទេសដែលត្រូវចំណាយច្រើនសម្រាប់ការដឹកជញ្ជូន ឯកសារនាំចូល សេវាឆ្លងដែន និងចំណាយផ្សេងៗទៀត។ ឧទាហរណ៍ នៅប្រទេសនីហ្សេរីយ៉ា ម្សៅដំឡូងមីត្រូវបានតម្រូវឱ្យលាយជាមួយម្សៅស្រូវសាលីយ៉ាងហោចណាស់ ១០ភាគរយសម្រាប់ធ្វើនំប៉័ង ដើម្បីកាត់បន្ថយការនាំចូលស្រូវសាលីដែលមានតម្លៃថ្លៃ ដែលប្រទេសនេះបានចំណាយលុយរាប់លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗ[១១]។ ចំណិតដំឡូងមីក្រៀមនិងស្លឹកដំឡូងមី ក្នុងអត្រា១ភាគ៤អាចជំនួស

---

[៨] ទីផ្សារដំឡូងមី CIAT (ឆ្នាំ ២០១៨) នៅពេលដែលភាពប្រាកដប្រជា គឺជាភាពច្បាស់លាស់តែមួយគត់ ខ្សែចង្វាក់តម្លៃ និងជីវភាពរស់នៅនៅអាស៊ី Cotonou, Benin

[៩] ការវិភាគ អាណត្តិ"Ethanol E10 នៅទូទាំងប្រទេសចិនប្រឈមនឹងឧបសគ្គ "https://www.patts.com/latest-news/agriculture / signapore / analysis-chinas-nationwide-e10-ethanol -mandate-26808971

[១០] ទីផ្សារម្សៅដំឡូងមីរបស់ IMAR (2017) និន្នាការសកល ចែករំលែក ទំហំ កំណើន ឱកាស និងការព្យាករ ២០១៧-២២ www.imarcgroup.com

[១១] លោក Elijah Ige Ohimain (ឆ្នាំ២០១៤) ការរំពឹងទុកនិងបញ្ហាប្រឈមនៃការដាក់បញ្ចូលដំឡូងទៅក្នុងគោលនយោបាយនំប៉័ងស្រូវសាលីនៅក្នុងប្រទេសនីហ្សេរីយ៉ា អង្គភាពស្រាវជ្រាវគោលនយោបាយឧស្សាហកម្ម និងអាហារ នាយកដ្ឋានវិទ្យាសាស្ត្រជីវសាស្ត្រ មហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យ Niger Delta

ពោតសម្រាប់ការផលិតចំណីសត្វនិងកាត់បន្ថយថ្លៃដើម ដោយមិនប៉ះពាល់ដល់ការរីកលូតលាស់ ការឡើងទម្ងន់ ឬលទ្ធភាពផលិតស៊ុតសត្វ[១២]។ ការស្រាវជ្រាវនៅប្រទេសឥណ្ឌូណេស៊ីបង្ហាញថា មីកែច្នៃពីម្សៅដំឡូងមីមានគុណភាពដូចគ្នាប្រមាណ៨០ភាគរយទៅនឹងមីធ្វើពីម្សៅស្រូវសាលី[១៣]។ នៅប្រទេសម៉ូសំប៊ិក ដំឡូងមីត្រូវបានគេប្រើប្រាស់ដើម្បីផលិតស្រាបៀរជំនួសឱ្យការនាំចូលស្រូវបាឡី (Barley)[១៤]។ នៅសហរដ្ឋអាម៉េរិក មានក្រុមហ៊ុនមួយកំពុងផលិតទឹកស្ករធម្មជាតិ (organic sweetener) ពីដំឡូងមីជំនួសស្ករអំពៅនិងពោត ព្រោះវាមានផលល្អសម្រាប់សុខភាពដោយសារតែស្ករនេះគ្មានជាតិគ្លុយតែន (Gluten) ដែលមិនធ្វើឱ្យអ្នកបរិភោគមានប្រតិកម្ម (Allergy) និងគ្មានសរីរាង្គបំប្លែងសេនេទិក (សរីរាង្គបម្រែបម្រួលហ្សែន) (Transgenetic Plant) មានកាឡូរីខ្ពស់និងមានជាតិសរសៃច្រើនដែលជួយកាត់បន្ថយជំងឺទឹកនោមផ្អែមនិងបេះដូង[១៥]។

ដោយសារលក្ខណៈពិសេសនេះហើយ បានជាធ្វើឱ្យផលិតផលដែលកែច្នៃពីដំឡូងមីមានទីផ្សារពិសេសដែលផលិតផលកែច្នៃចេញពីពោត ស្រូវសាលី អង្ករ និងដំឡូងបារាំងមិនអាចជំនួសបាន។ ទោះបីជាមានអ្នកទិញមានឆន្ទៈផ្តល់តម្លៃខ្ពស់សម្រាប់ផលិតផលកែច្នៃពីដំឡូងមី (ជាពិសេសម្សៅដំឡូងមីសរីរាង្គ)ក៏ដោយ ទីផ្សារទាំងនេះមានការប្រកួតប្រជែងខ្លាំង ហើយការបង្កើតប្រព័ន្ធអនុលោមផលិតផលដំឡូងមីនឹងស្តង់ដាសរីរាង្គនិងការទទួលបានផ្លាកសញ្ញាបញ្ជាក់គុណភាព ត្រូវការដើមទុនវិនិយោគដំបូងច្រើននិងពេលវេលាយូរសម្រាប់ការរៀបចំប្រព័ន្ធការងារនិងកសាងសមត្ថភាពដល់ភាគីពាក់ព័ន្ធ ដែលនេះជាកត្តាប្រឈមសម្រាប់សហគមន៍ និង/ឬ សហគ្រាសធុនតូចនិងមធ្យម។ សម្រាប់តែម្សៅដំឡូងមីសរីរាង្គតែមួយមុខគត់ តម្រូវការរបស់វាកើនឡើង១ ០០០ដង ក្នុងរយៈពេល១០ឆ្នាំដែលចាប់ពី៦០តោននៅឆ្នាំ២០០៧ ដល់ ៦០ ០០០តោននៅឆ្នាំ២០១៧[១៦]។

ការដាំដុះនិងពាណិជ្ជកម្មដំឡូងមីត្រូវបានប្រមើលមើលឃើញថា នឹងមានភាពអំណោយផលល្អសម្រាប់ភូមិភាគអាស៊ីអាគ្នេយ៍នាពេលអនាគត ព្រោះទិន្នផលរបស់វាអាចប្រកួតប្រជែងជាមួយពោតនិងដំណាំជំនួសផ្សេងទៀតសម្រាប់ការកែច្នៃម្សៅ អេតាណុល និងផលិតផលផ្សេងៗ។ ប្រទេសចិននិងតំបន់អាស៊ីខ្វះខាតអាហារដែលមានជាតិកាបូអ៊ីដ្រាតច្រើន (ម្សៅ ស្ករ និងសៃលុយឡូស ដែលផ្តល់ថាមពលដល់មនុស្សនិងសត្វ) ប៉ុន្តែកង្វះខាតនេះត្រូវបានបំពេញគ្រប់គ្រាន់មកវិញតាមតម្រូវការ ដោយខ្សែច្រវាក់តម្លៃផ្គត់ផ្គង់ដំឡូងមីក្នុងតំបន់និងពិភពលោក។ នៅក្នុងសហភាពអឺរ៉ុប ម្សៅដំឡូងបារាំងទទួលបានកិច្ចគាំពារនិងគាំទ្រច្រើនពីរដ្ឋ ដែលបង្កើតការទុកចិត្តដល់អតិថិជនជាពិសេស អ្នកផលិតក្រដាសនិងម្ហូបអាហារ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដោយសារការដកការឧបត្ថម្ភធនចេញពីដំណាំពោត បានធ្វើឱ្យតម្លៃពោតនៅប្រទេសចិនធ្លាក់ចុះនិងប្រែប្រួលតាមតម្លៃទីផ្សារពោតអន្តរជាតិ (អាម៉េរិក) និងបានធ្វើឱ្យតម្លៃដំឡូងមីធ្លាក់ចុះស្របគ្នា។ ដូច្នេះ អនាគតដំឡូងមីកម្ពុជានិងតំបន់អាស៊ីអាគ្នេយ៍ត្រូវពឹងផ្អែកលើលទ្ធភាពរបស់ខ្លួនក្នុងការរក្សាភាពប្រកួតប្រជែងជាមួយនឹងពោតនិងដំណាំជំនួសដែលដាំដុះនៅតំបន់ផ្សេងៗក្នុងពិភពលោក។ ភាពប្រកួតប្រជែងរបស់ដំឡូងមីដែលត្រូវរក្សានិងបង្កើន រួមមាន ទិន្នផលខ្ពស់ ថ្លៃដើមផលិតទាប គុណភាពម្សៅល្អ និងការផ្គត់ផ្គង់បានតាមបរិមាណតម្រូវការរបស់អតិថិជនប្រកបដោយការទុកចិត្ត។

---

[១២] http://www.cassavabiz.org/postharvest/lvstock_1.htm

[១៣] Akhmad Zainal Abidin (ឆ្នាំ២០១៣) ការអភិវឌ្ឍមីកញ្ចប់ដោយប្រើម្សៅដំឡូងមី(វិទ្យាស្ថានបច្ចេក Bandung)

[១៤] Agence France-Presse (ឆ្នាំ២០១៧) លើសពីស្រូវអង្ករ ការផលិតស្រាបៀរពីផលិតផលដំឡូងមីបង្កការភ្ញាក់ផ្អើលនៅទីផ្សារ

[១៥] Madhava, ដំឡូងមីសរីរាង្គ www.madhavasweenteners.com

[១៦] មជ្ឈមណ្ឌលសម្រាប់បច្ចេកវិទ្យាគ្រប់គ្រងទី ៧ នៃម្សៅដំឡូងមីនៅពិភពអាស៊ី ថ្ងៃទី ២៣-២៥ ខែ មករា ឆ្នាំ ២០១៨ សៀមរាប

## ២. ចក្ខុវិស័យ

គោលនយោបាយជាតិនេះ មានចក្ខុវិស័យកសាងមូលដ្ឋានផលិតកម្មដំឡូងមីប្រកបដោយនិរន្តរភាពសម្រាប់ការកែច្នៃប្រកបដោយគុណភាពដើម្បីប្រកួតប្រជែងនៅលើទីផ្សារ។

## ៣. គោលបំណងនិងគោលដៅ

គោលនយោបាយជាតិនេះ មានគោលបំណងធ្វើឱ្យប្រទេសកម្ពុជាក្លាយជាទីតាំងផលិតនិងកែច្នៃដំឡូងមី និងជាអ្នកផ្គត់ផ្គង់ផលិតផលដំឡូងមីមួយ ដែលអាចជឿទុកចិត្តបានសម្រាប់ទីផ្សារពិភពលោក។

ដើម្បីសម្រេចបាននូវចក្ខុវិស័យនិងគោលបំណងខាងលើ **គោលនយោបាយជាតិនេះ**កំណត់គោលដៅសំខាន់ៗចំនួនបីដូចខាងក្រោម៖

- ផ្លាស់ប្តូរពីផលិតកម្មដំឡូងមីបែបប្រពៃណីឬគ្រួសារ ទៅជាផលិតកម្មដំឡូងមីបែបពាណិជ្ជកម្មនិងអនុវត្តតាមគោលការណ៍បច្ចេកទេស ដែលកសិករអាចទទួលបានប្រាក់ចំណូលក្នុងបរិបទដែលថ្លៃដំឡូងមីប្រែប្រួល ការប្រើប្រាស់ដីប្រកបដោយនិរន្តរភាព និងកសិកម្មវៃឆ្លាតដែលធន់នឹងការប្រែប្រួលអាកាសធាតុ
- គាំទ្រដល់អ្នកកែច្នៃផលិតផលដំឡូងមីដែលមានសក្តានុពលនិងទាក់ទាញវិនិយោគ ដើម្បីកែច្នៃផលិតផលដំឡូងមីដែលមានតម្លៃបន្ថែមសម្រាប់ផ្គត់ផ្គង់ទីផ្សារនានា
- លើកកម្ពស់ភាពប្រកួតប្រជែងពាណិជ្ជកម្ម តាមរយៈការជ្រៀតចូលនិងចាប់យកចំណែកទីផ្សារ កែលម្អកិច្ចសម្រួលពាណិជ្ជកម្ម កាត់បន្ថយចំណាយដែលមិនចាំបាច់ និងផ្សារភ្ជាប់នឹងអន្តរវិស័យដែលពាក់ព័ន្ធក្នុងការនាំចេញ។

## ៤. យុទ្ធសាស្ត្រដើម្បីសម្រេចគោលនយោបាយ

គោលនយោបាយជាតិ ស្តីពីដំឡូងមីកំណត់យុទ្ធសាស្ត្រប្រមូលផ្តុំ ដែលកំណត់យកកម្រិតទាំងបីនៅក្នុងខ្សែប្រវាក់តម្លៃដំឡូងមី រួមមាន ការផលិត ការកែច្នៃ និងការនាំចេញ ត្រូវអភិវឌ្ឍក្នុងពេលតែមួយស្របគ្នា៖

**៤.១. យុទ្ធសាស្ត្រនៃការផលិត** : ទីផ្សារត្រូវបានកំណត់ជាមុន ហើយបន្ទាប់មកខ្សែប្រវាក់តម្លៃផ្គត់ផ្គង់ត្រូវបានរៀបចំតម្រឹមនិងបន្សីគ្នា។ តួអង្គសំខាន់ៗ ដូចជា កសិករនិងអ្នកកែច្នៃត្រូវលើកទឹកចិត្តនិងសម្របសម្រួលឱ្យសហការជាមួយគ្នា តាមរយៈផលិតកម្មកសិកម្មតាមកិច្ចសន្យា គ្រោងការផលិតកម្ម និងយន្តការផ្សេងទៀតដែលអាចអនុវត្តបានដោយជោគជ័យ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ខ្សែប្រវាក់តម្លៃមូលដ្ឋានត្រូវបង្កើតឡើង ហើយផែនការវិនិយោគរបស់តួអង្គទាំងនេះត្រូវធ្វើឱ្យមានសង្គតិភាពនឹងគ្នា ដើម្បីបង្កើនប្រសិទ្ធភាពខ្សែប្រវាក់តម្លៃទាំងមូល។ គោលដៅនានាត្រូវកំណត់ជាមុននិងសហការអនុវត្ត ដូចជាប្រតិទិនដាំដុះ ទិន្នផល ថ្លៃដើមផលិតកម្ម ការគ្រប់គ្រងគុណភាព ផែនការប្រមូលផលនិងកែច្នៃ និងការគ្រប់គ្រងហានិភ័យ។ វិនិយោគសាធារណៈ(រាជរដ្ឋាភិបាលនិងភាគីពាក់ព័ន្ធ) ត្រូវផ្តោតលើតំបន់ដែលវិស័យឯកជនបានបោះទុនវិនិយោគសាងសង់រោងចក្រនិងមានកសិករដាំដុះដំឡូងមីច្រើន។

**៤.២. យុទ្ធសាស្ត្រនៃការកែច្នៃ** : ការជួយគាំទ្រអ្នកកែច្នៃដែលមានស្រាប់ និងទាក់ទាញវិនិយោគដែលមានធនធានហិរញ្ញវត្ថុនិងបទពិសោធពាណិជ្ជកម្ម គឺជាចំណុចចាប់ផ្តើមនៃការផ្លាស់ប្តូរវិស័យនេះ ដើម្បីជំរុញខ្សែប្រវាក់តម្លៃដំឡូងមីឱ្យឈានឡើងមួយកម្រិតទៀត។ ឧស្សាហកម្មកែច្នៃដំឡូងមីកម្ពុជាត្រូវតែមានសមត្ថភាព

ដូចគ្នាឬប្រហាក់ប្រហែលគ្នានឹងឧស្សាហកម្មកែច្នៃដំឡូងមីបរទេស ដែលថ្លៃដើមផលិតផលអាចប្រកួតប្រជែងអាចទាញយកប្រយោជន៍ទាំងអស់ពីមើមដំឡូងមី(សំណល់) និងប្រើប្រាស់បច្ចេកវិទ្យាជឿនលឿនដើម្បីកាត់បន្ថយការបំពុលបរិស្ថាន។ ការវិនិយោគទាំងនេះត្រូវមានការគាំទ្រនិងលើកទឹកចិត្តពីផ្នែកគោលនយោបាយពន្ធនិងហិរញ្ញប្បទានដែលមានអត្រាការប្រាក់ទាបប្រកបដោយនិរន្តរភាព។

ឧស្សាហកម្មកែច្នៃដំឡូងមីត្រូវផ្សារភ្ជាប់ជាមួយវិស័យពាក់ព័ន្ធដទៃទៀត ដើម្បីធ្វើឱ្យសេដ្ឋកិច្ចមូលដ្ឋានមានចរន្តរស់រវើក ដែលបង្កើតបាននូវគុណតម្លៃបន្ថែមនិងផ្ដល់អត្ថប្រយោជន៍បំពេញឱ្យគ្នាទៅវិញទៅមក។ ដូចជា សំណល់ពីការកែច្នៃម្សៅដំឡូងមីឬអេតាណុលអាចយកទៅលាយជាមួយនឹងពោត ចុងអង្ករ ឬសណ្ដែកសៀងជាដើម ដើម្បីធ្វើជាចំណីសត្វសម្រាប់ទីផ្សារក្នុងស្រុក។ ដូច្នេះវាអាចជំនួសការនាំចូលចំណីសត្វពីបរទេសបានមួយចំនួន។ យោងតាមស្ថិតិពីមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ(ITC) ប្រទេសកម្ពុជាបាននាំចូលចំណីសត្វមានតម្លៃប្រហែល៦៣លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០១៦។

សំណល់ពីដំឡូងមីក៏អាចធ្វើជាជីសម្រាប់លក់ទៅឱ្យកសិករក្នុងតម្លៃទាបជាងជីដែលនាំចូល។ បន្ថែមលើនេះ សំណល់រាវពីដំឡូងមី(ទឹកលាងដំឡូងមីឬចេញពីល្បាយម្សៅមី) អាចធ្វើជាទឹកជីសរីរាង្គសម្រាប់ស្រោចស្រពចម្ការដំណាំរបស់កសិករដែលនៅជិតរោងចក្រនិងបង្កើតជីវឧស្ម័នដើម្បីដុតយកកម្ដៅសម្ងួតម្សៅដំឡូងមីនិងបង្កើតថាមពលអគ្គិសនីសម្រាប់ប្រើប្រាស់។ ទឹកដែលបានធ្វើប្រព្រឹត្តិកម្មនិងអគ្គិសនីដែលនៅសល់ពីរោងចក្រផលិតម្សៅមីឬអេតាណុល ត្រូវបានផ្ដល់ឬលក់ទៅឱ្យសហគមន៍ក្នុងតម្លៃសមរម្យឬទាបជាងទីផ្សារ ដើម្បីលើកទឹកចិត្តដល់កសិករបន្តផ្គត់ផ្គង់ដំឡូងមីដល់រោងចក្រ។ ដោយសារដំឡូងមីមានផ្ទុកសារធាតុស្យានីដអ៊ីដ្រូសែន(HCN)ខ្ពស់ ការបំពុលដែលកើតចេញពីសារធាតុនេះត្រូវត្រួតពិនិត្យឱ្យបានត្រឹមត្រូវនិងហ្មត់ចត់នៅគ្រប់ដំណាក់កាលនៃការកែច្នៃទាំងអស់ដើម្បីការពារប្រព័ន្ធអេកូឡូស៊ីកសិកម្ម ជីវចម្រុះនិងសុខុមាលភាពសហគមន៍។

**៤.៣. យុទ្ធសាស្ត្រនៃការនាំចេញ** : ដំឡូងមីជាដំណាំមួយប្រភេទដែលកសិករងាយនឹងបោះបង់ឬផ្លាស់ទៅដាំដំណាំផ្សេងទៀត នៅពេលដែលតម្លៃថយចុះខ្លាំង ហើយទីផ្សារមិនច្បាស់លាស់។ ការកែលម្អលទ្ធភាពបង្កើនប្រាក់ចំណេញរបស់កសិករ ជាពិសេសកសិកររស់នៅក្នុងតំបន់ដែលអំណោយផលដល់ការដាំដុះដំឡូងមី គឺជាអាទិភាពចាំបាច់មួយដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេនិងគាំទ្រដល់ផែនការអាជីវកម្មរយៈពេលវែងរបស់រោងចក្រឧស្សាហកម្មកែច្នៃ។

ពាណិជ្ជូបនីយកម្មកសិកម្មដំឡូងមីត្រូវផ្ដើមចេញនិងជំរុញដោយការស្រាវជ្រាវនិងការអភិវឌ្ឍប្រព័ន្ធផលិតកម្មកសិកម្មមូលដ្ឋាន។ បញ្ហាផលិតកម្មដែលនាំឱ្យមានការខាតបង់សេដ្ឋកិច្ចត្រូវដោះស្រាយស្របតាមតម្រូវការនិងទាន់ពេលវេលា ដូចជា សមាសភាពចង្រៃ ការអនុវត្តកសិកម្មដែលមិនមាននិរន្តរភាព ការហូរច្រោះដី ការប្រើប្រាស់ពូជដែលគ្មានគុណភាព និងការប្រែប្រួលអាកាសធាតុ។ល។ បន្ថែមលើនេះ ការបង្កើនការធ្វើយន្តូបនីយកម្មកសិកម្ម ដើម្បីជំនួសការងារដែលប្រើកម្លាំងពលកម្មខ្លាំង កាត់បន្ថយលើការចំណាយលើថ្លៃឈ្នួលពលកម្មដែលកំពុងបន្តកើនឡើង និងដោះស្រាយវិបត្តិកង្វះខាតកម្លាំងពលកម្មនៅជនបទត្រូវតែយកចិត្តទុកដាក់បន្ថែមទៀត។ ជាតុចូលកសិកម្ម(ជី ថ្នាំ ពូជ) ត្រូវត្រួតពិនិត្យនិងកែលម្អឱ្យប្រសើរឡើងថែមទៀត តាមរយៈការបង្កើនការយល់ដឹងនិងការកំណត់ការទទួលខុសត្រូវដល់អ្នកលក់និងអ្នកចែកចាយ

ជាតុចូលកសិកម្ម ដើម្បីឱ្យពួកគេផ្គត់ផ្គង់តែផលិតផលដែលមានគុណភាព និងណែនាំអតិថិជនរបស់ពួកគេឱ្យប្រើប្រាស់ផលិតផលឱ្យបានត្រឹមត្រូវប្រកបដោយសុវត្ថិភាពនិងមានប្រសិទ្ធភាព។ ការផ្តល់ប្រាក់កម្ចីគួរថ្លៃប្រនិតឱ្យស្របតាមតម្រូវការ ប្រតិបត្តិការចំណាយ និងលំហូរសាច់ប្រាក់របស់កសិករផ្អែកតាមប្រតិទិនដាំដុះដំឡូងមី ព្រមទាំងផ្តល់ការអនុគ្រោះចំពោះការសងកម្ចីយឺត ដើម្បីបញ្ចៀសការគាស់លក់ដំឡូងមីមិនគ្រប់អាយុឬលក់ក្រោមតម្លៃទីផ្សារក្នុងស្ថានភាពមិនស្មើភាព និងផ្តល់ការប្រឹក្សាយោបល់ដើម្បី ជួយពួកគេឱ្យប្រើប្រាស់កម្ចីប្រកបដោយប្រសិទ្ធភាពនិងចំគោលដៅ។

## ៥. ផែនការសកម្មភាព

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រនៃគោលនយោបាយនេះ ផែនការសកម្មភាពដែលត្រូវអនុវត្តចាំបាច់រួមមាន៖

### ៥.១. ការបង្កើតយន្តការ

ដើម្បីអនុវត្តគោលនយោបាយជាតិដំឡូងមីនេះប្រកបដោយប្រសិទ្ធភាព រចនាសម្ព័ន្ធគ្រប់គ្រងវិស័យដំឡូងមីចាំបាច់ត្រូវបង្កើតឡើងសំដៅសម្របសម្រួល ប្រមូលផ្តុំ តម្រង់ទិស និងភ្ជាប់ទំនាក់ទំនងរវាងផ្នែកពាក់ព័ន្ធទាំងអស់ដែលអាចដោះស្រាយបាននូវការខ្វះខាតនិងឈានទៅអភិវឌ្ឍវិស័យនេះឱ្យមាននិរន្តរភាព។ ក្រសួង/ស្ថាប័នពាក់ព័ន្ធត្រូវកៀរគរធនធានបន្ថែមស្របតាមការចាំបាច់នៃទំហំការងារ ដើម្បីជំរុញអនុវត្តគោលនយោបាយនេះ ត្រូវចាត់តាំងឱ្យអនុវត្តភារកិច្ចដែលស្ថិតក្នុងដែនសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ខ្លួន ហើយធនធានមនុស្សនិងហិរញ្ញវត្ថុត្រូវផ្តល់ឱ្យបន្ថែមស្របតាមការចាំបាច់និងទំហំការងារ។ ក្នុងការជំរុញអនុវត្តគោលនយោបាយជាតិដំឡូងមីនេះប្រកបដោយប្រសិទ្ធភាពនិងសង្គតិភាព ត្រូវបង្កើតយន្តការដូចខាងក្រោម៖

៥.១.១. ក្រុមការងារដំឡូងមី ដែលបានបង្កើតឡើងដោយក្រសួងពាណិជ្ជកម្ម តាមរយៈប្រកាសលេខ២៧៣ ព.ណ គនព. ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ នឹងក្លាយជាក្រុមការងារផ្លូវការមួយនៃវេទិការវាងរាជរដ្ឋាភិបាល និងវិស័យឯកជន។ ក្រុមការងារនេះមានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលស្ថិតក្រោមក្រសួងពាណិជ្ជកម្ម។

៥.១.២. ក្រុមជំនាញ (Think Tank) ដែលមានសមត្ថភាពក្នុងការប្រមូលទិន្នន័យ វិភាគទីផ្សារ វាយតម្លៃឧត្តមភាពប្រកួតប្រជែងរបស់តួអង្គផ្សេងៗក្នុងចង្វាក់តម្លៃ។

៥.១.៣. បង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ផលិតផលនិងនវានុវត្តន៍ ដើម្បីស្រាវជ្រាវ ពិសោធ និងបង្កើតផលិតផលថ្មីៗ ដែលមានតម្រូវការទីផ្សារ តម្លៃបន្ថែមច្រើន និងមានលំនឹងតម្លៃ។

៥.១.៤. ពង្រឹងសមត្ថភាពរបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា(CARDI)និងស្ថានីយពិសោធន៍ស្រាវជ្រាវផ្សេងៗទៀត ដើម្បីស្រាវជ្រាវបង្កើតពូជដំឡូងមីដែលមានម្សៅច្រើន គុណភាពម្សៅខ្ពស់ ជួយដល់កសិករអនុវត្តកសិកម្មប្រកបដោយនិរន្តរភាព វៃឆ្លាត និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ បន្ថែមលើនេះ ក៏ជួយបង្កើតប្រព័ន្ធផ្គត់ផ្គង់ដំឡូងមីដ៏គួរឱ្យជឿជាក់ដល់រោងចក្រឧស្សាហកម្មកែច្នៃ។

### ៥.២. ការបង្កើតក្របខ័ណ្ឌគតិយុត្ត

ការអនុវត្តគោលនយោបាយនេះត្រូវអនុលោមតាមច្បាប់និងមានការគាំទ្រដោយលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន។ ក្រសួងស្ថាប័នរាជរដ្ឋាភិបាល អាចរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យដំឡូងមី ស្របតាមការចាំបាច់និងតម្រូវការជាក់ស្តែង។

### ៥.៣_ ការគាំទ្រហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារជាតិនៃកម្ពុជា មានការកិច្ចរួមគ្នាក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងការផ្តល់ហិរញ្ញប្បទានស្របតាមស្មារតីនៃឯកសារគោលនយោបាយនេះ។ ទន្ទឹមនឹងនេះ ហិរញ្ញប្បទានអាចបានមកពីអំណោយពីដៃគូអភិវឌ្ឍ វិស័យឯកជន ព្រមទាំងថវិកាមកពីប្រភពស្របច្បាប់ផ្សេងទៀត។

### ៥.៤_ ការបណ្តុះបណ្តាលធនធានមនុស្ស

ធនធានមនុស្សគឺជាកម្លាំងស្នូល ដើម្បីសម្រេចចក្ខុវិស័យនិងអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាព។ ដើម្បីបណ្តុះបណ្តាលធនធានមនុស្ស សំដៅបង្កើនផលិតភាពដំឡូងមី វិទ្យាស្ថានស្តង់ដាកម្ពុជា វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្មនិងស្រាវជ្រាវ(TTRI) វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា(CARDI) ត្រូវកំណត់កម្មវិធីបណ្តុះបណ្តាលនិងស្រាវជ្រាវ ដើម្បីចូលរួមគាំទ្រដល់វិស័យដំឡូងមី និងរៀបចំនីតិវិធីដើម្បីកំណត់ស្តង់ដាដំឡូងមី រួមទាំងការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ទស្សនកិច្ចសិក្សាក្នុងនិងក្រៅប្រទេស។ល។

### ៥.៥_ ហេដ្ឋារចនាសម្ព័ន្ធ

ស្របតាមការរីកចម្រើននៃវិស័យដឹកជញ្ជូនពាណិជ្ជកម្មអន្តរជាតិនិងសមាហរណកម្មរបស់កម្ពុជាក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចនិងពិភពលោក ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់វិស័យដំឡូងមី ហេដ្ឋារចនាសម្ព័ន្ធត្រូវយកចិត្តទុកដាក់ស្តារនិងពង្រឹងបន្ថែម៖

៥.៥.១. សម្រួលនិងធ្វើឱ្យមានភាពស្របគ្នារវាងផែនការភស្តុភារកម្មនិងគោលនយោបាយតាមរយៈការពង្រីកសមត្ថភាពកំពង់ផែ ពង្រឹងប្រសិទ្ធភាពសេវាកម្មភស្តុភារ កិច្ចសម្រួលពាណិជ្ជកម្ម និងឃ្លាំងស្តុក។

៥.៥.២. ពិនិត្យលទ្ធភាពក្នុងការកសាងផ្លូវដឹកជញ្ជូនយុទ្ធសាស្ត្រ ដែលកាត់បន្ថយចម្ងាយដឹកជញ្ជូនពីកន្លែងកែច្នៃទៅកំពង់ផែឬច្រកនាំចេញ និងតភ្ជាប់ពីរោងចក្រឧស្សាហកម្មកែច្នៃទៅបណ្តាញដឹកជញ្ជូនជាតិ(ផ្លូវរថភ្លើង ផ្លូវទឹក ផ្លូវជាតិ) និងកសាងសេវាសាធារណៈផ្សេងៗដូចជា ទឹក ភ្លើង ប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តិកម្មទឹកស្អាត។ល។

៥.៥.៣. ពិនិត្យលទ្ធភាពក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលចាំបាច់សម្រាប់គាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធឯកជនរបស់រោងចក្រឧស្សាហកម្មកែច្នៃ ដើម្បីគ្រប់គ្រងសំណល់និងការបំពុលបរិស្ថានប្រកបដោយប្រសិទ្ធភាព និងអនុលោមតាមច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងផលប៉ះពាល់បរិស្ថាន ក៏ដូចជាកែច្នៃសំណល់ទាំងនោះទៅជាពហុផលិតផលដែលមានអត្ថប្រយោជន៍ដល់សហគមន៍មូលដ្ឋាន។

### ៥.៦_ ដំណើរការអនុវត្តគម្រោង

ដោយសារការអភិវឌ្ឍវិស័យដំឡូងមីផ្សារភ្ជាប់នឹងការអភិវឌ្ឍវិស័យកសិកម្មនិងពាណិជ្ជកម្ម គោលនយោបាយនេះត្រូវអនុវត្តទុកឱ្យស្របជាមួយនឹងយុទ្ធសាស្ត្រជាតិនិងគោលនយោបាយពាក់ព័ន្ធនានា ដើម្បីបំពេញឱ្យគ្នាទៅវិញទៅមកក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនិងប្រសិទ្ធផលក្នុងការអភិវឌ្ឍវិស័យដំឡូងមី។ បញ្ហាអន្តរវិស័យ ដូចជា ថ្លៃដឹកជញ្ជូនខ្ពស់ សេវាកម្មភស្តុភារមានកម្រិត កម្ចីហិរញ្ញវត្ថុមានអត្រាការប្រាក់ខ្ពស់ ថ្លៃអគ្គិសនីខ្ពស់ និងការផ្គត់ផ្គង់មានភាពអាក់រអួល កិច្ចសម្រួលពាណិជ្ជកម្មនៅមិនទាន់ជឿជាក់បានដូចការរំពឹងទុក កង្វះខាតសម្ភារៈគាំទ្រសកម្មភាពពាណិជ្ជកម្មនៅកំពង់ផែឬច្រកនាំចេញ និងកង្វះទីផ្សារពលកម្មក្នុងស្រុកក្នុងការផ្តល់បុគ្គលិកឬពលករជំនាញដល់វិស័យឯកជន ត្រូវដោះស្រាយនៅក្នុងក្របខ័ណ្ឌអភិវឌ្ឍជាតិរួមមួយនិងឆ្លើយតបចំពោះតម្រូវការជាក់លាក់

របស់វិស័យដំឡូងមី។ គោលនយោបាយជាតិដំឡូងមី ជាគំរូមួយដែលស្របនិងមានសង្គតិភាពជាមួយយុទ្ធសាស្ត្រចតុកោណថ្មីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ផែនការមេភស្តុភារកម្ម(ឡូជីស្ទីក) យុទ្ធសាស្ត្រកសិកម្មនិងទឹក និងគោលនយោបាយនាំចេញអង្ករ។

ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវបន្តអនុវត្តកំណែទម្រង់ ដើម្បីកាត់បន្ថយការចំណាយមិនចាំបាច់ និងបង្កើតតម្លៃបន្ថែមដើម្បីលើកកម្ពស់ការប្រកួតប្រជែងរបស់វិស័យនេះ សម្រាប់ការជ្រៀតចូលនិងចាប់យកទីផ្សារដំឡូងមីថ្មីៗប្រកបដោយជោគជ័យ។ ទន្ទឹមនឹងនេះ ការអនុម័តនិងអនុវត្តវិធានការនៃគោលនយោបាយជាតិដំឡូងមី ត្រូវធានាបាននូវផលចំណេញនៃខ្សែច្រវាក់តម្លៃតាមរយៈការបង្កើនផលិតភាពរបស់តួអង្គនីមួយៗនិងការតភ្ជាប់គ្នារវាងតួអង្គពាក់ព័ន្ធ ដូចជា កសិករ រោងចក្រកែច្នៃ សេវាកម្មដឹកជញ្ជូន ធនាគារ ភ្នាក់ងារទីផ្សារ អ្នកទិញជាដើម ដើម្បីបង្កើនប្រសិទ្ធភាពនៃខ្សែច្រវាក់តម្លៃដំឡូងមី។ ដូច្នេះ ផលិតផលដំឡូងមីកម្ពុជាដែលស្របនឹងតម្លៃទីផ្សារអន្តរជាតិ នឹងមានគុណភាពស្របតាមតម្រូវការរបស់ទីផ្សារដែលតួអង្គនីមួយៗ អាចទទួលបានប្រាក់ចំណេញ។

ដើម្បីជំរុញការអភិវឌ្ឍវិស័យនេះឱ្យបានលឿន ក្រសួងសំខាន់ៗត្រូវសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីរៀបចំបង្កើតនិងអនុវត្តគម្រោងនានាដែលបំពេញចន្លោះប្រហោងរបស់គម្រោងវិនិយោគរបស់វិស័យឯកជននិងកសិករ។ កិច្ចសហប្រតិបត្តិការនេះត្រូវអនុវត្តក្នុងទម្រង់ភាពជាដៃគូរវាងអ្នកផលិតវិស័យសាធារណៈនិងវិស័យឯកជន(Producer Public Private Partnership)។ ដូច្នេះ ធនធានត្រូវប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនិងមុខងារត្រូវបានអនុវត្តស្របគ្នា ដើម្បីសម្រេចបាននូវគោលដៅរួម។

ដោយសារតម្លៃដំឡូងមីមានការប្រែប្រួលនិងពិបាកគ្រប់គ្រង ខ្សែច្រវាក់តម្លៃត្រូវតែកែលម្អដើម្បីបង្កើនលទ្ធភាពទទួលបានប្រាក់ចំណេញរបស់តួអង្គពាក់ព័ន្ធ ដោយផ្អែកលើតម្លៃដំឡូងមីទាបបំផុតដែលបានកត់ត្រានៅក្នុងបណ្តាឆ្នាំកន្លងមក។ ការបង្កើនលទ្ធភាពនេះ ត្រូវធ្វើឡើងតាមរយៈការលើកកម្ពស់ផលិតភាពរបស់តួអង្គនីមួយៗ ការផ្សារភ្ជាប់រវាងតួអង្គខ្សែផ្តេកនិងខ្សែឈរ ដើម្បីដោះស្រាយបញ្ហាដែលកើតមានក្នុងខ្សែច្រវាក់តម្លៃផលិតកម្មដំឡូងមី និងការកសាងប្រព័ន្ធអភិបាលកិច្ចមួយ ដើម្បីធ្វើឱ្យវិស័យដំឡូងមីនេះស៊ីចង្វាក់គ្នានឹងវិស័យពាក់ព័ន្ធផ្សេងៗដែលផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។

### ៥.៦.១_ គម្រោងរយៈពេលប្រាំឆ្នាំ

ផលិតភាពនៃផលិតកម្មដំឡូងមីនៅកម្ពុជាត្រូវបានបង្កើនតាមរយៈការបង្កើនទិន្នផលនិងការកាត់បន្ថយថ្លៃដើមផលិតកម្ម ដោយគ្មានហានិភ័យដល់ប្រព័ន្ធអេកូឡូស៊ី(ដំណាក់កាលទី១ - រយៈពេលពីរឆ្នាំ) និងលើកកម្ពស់ភាពប្រកួតប្រជែងខ្សែច្រវាក់តម្លៃ ដើម្បីបង្កើនប្រាក់ចំណូលរបស់កសិករនិងកំណើននៃឧស្សាហកម្មកែច្នៃ(ដំណាក់កាលទី២ - រយៈពេលបីឆ្នាំ)[១៧]៖

***ក_ ផលិតភាពនៃផលិតកម្មដំឡូងមីនៅកម្ពុជាត្រូវបានបង្កើនតាមរយៈការបង្កើនទិន្នផលនិងការកាត់បន្ថយថ្លៃដើមផលិតកម្ម ដោយគ្មានហានិភ័យដល់ប្រព័ន្ធអេកូឡូស៊ីកសិកម្ម៖***

ក.១_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើការសិក្សាលើផែនការផលិតកម្មនិងតំបន់ដាំដុះដំណាំដំឡូងមីជាទៀងទាត់ ដើម្បីកត់ត្រាទំហំផលិតកម្ម កំណត់តំបន់ដាំដុះ តាមជានដីជាតិដី និងថ្លៃដើមផលិតកម្ម។ ហ៥

[១៧] សម្រាប់សកម្មភាពលម្អិតនៃដំណាក់កាលខ្លីនិងមធ្យម ព្រមទាំងសកម្មភាពសម្រាប់ទស្សនវិស័យរយៈពេលវែង សូមពិនិត្យឧបសម្ព័ន្ធទី១

ផ្អែកលើការសិក្សានេះខ្សែក្រវាត់ដំឡូងមី(តំបន់)គួរតែកំណត់និងបង្កើតឡើង ដើម្បីលើកទឹកចិត្តនិងជំរុញដល់កសិករប្រើប្រាស់ដីដែលសមស្របបំផុតសម្រាប់ការដាំដុះដំឡូងមី ដើម្បីធានានូវនិរន្តរភាពបរិស្ថាន សេដ្ឋកិច្ច និងសង្គម។ ខ្សែក្រវាត់ដំឡូងមី(តំបន់) ត្រូវចាត់ទុកជាឧបករណ៍មួយសម្រាប់គ្រប់គ្រងការដាំដុះតាមគោលការណ៍និរន្តរភាពនិងជួយបង្កលក្ខណៈងាយស្រួលដល់អ្នកកែច្នៃទទួលបានវត្ថុធាតុដើម(មើមដំឡូងមី) ប្រកបដោយអនុលោមភាពនិងគុណភាពដែលពួកគេចង់បាន។

ក.២_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវត្រួតពិនិត្យអនាម័យនិងភូតគាមអនាម័យលើការនាំចូលពូជនិងដើមដំឡូងមីពីបរទេស ដើម្បីការពារនិងទប់ស្កាត់ការរីករាលដាលនៃសមាសភាពចង្រៃពីតំបន់មួយទៅតំបន់មួយ ដែលអាចបង្កឱ្យមានការខាតបង់ដល់សេដ្ឋកិច្ចជាតិ។ ការគំរាមកំហែងដែលបានរកឃើញ ត្រូវទប់ស្កាត់និងដោះស្រាយដោយវិធានការអនាម័យនិងភូតគាមអនាម័យយ៉ាងតឹងរ៉ឹងនិងតាមរយៈយន្តការដែលមានស្រាប់។

ក.៣_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចរចាជាមួយដៃគូជាសមាសភាគីរបស់ខ្លួននៃបណ្តាប្រទេសនានា មជ្ឈមណ្ឌលស្រាវជ្រាវ និងវិទ្យាស្ថានស្រាវជ្រាវអន្តរជាតិ ដើម្បីនាំចូលពូជដំឡូងមីដែលផ្តល់ទិន្នផលខ្ពស់ធន់នឹងជំងឺ ធន់នឹងការប្រែប្រួលអាកាសធាតុ យកមកធ្វើការសាកល្បងនៅកម្ពុជា ដើម្បីផ្សព្វផ្សាយនិងចែកចាយដល់កសិករ ប្រសិនបើពូជទាំងនោះសមស្របនឹងលក្ខខណ្ឌអាកាសធាតុ ដី និងកត្តាផ្សេងៗទៀត។

ក.៤_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលើកទឹកចិត្តដល់ស្ថាប័នពាក់ព័ន្ធនិងវិស័យឯកជនឱ្យមានថ្នាលបណ្តុះពូជនិងដើមដំឡូងមី ដើម្បីផលិតនិងចែកចាយពូជនិងដើមដែលមានគុណភាព គ្មានជំងឺ ស្របតាមលក្ខណៈដីរបស់កសិករនិងតម្រូវការរបស់អ្នកកែច្នៃ។

ក.៥_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវពិនិត្យតាមដាននិងវាយតម្លៃគុណភាពធាតុចូលកសិកម្ម(ដូចជា ជី)ដែលកំពុងប្រើប្រាស់លើដំណាំដំឡូងមី ដើម្បីធានាប្រសិទ្ធភាពរបស់វាក្នុងការបង្កើនទិន្នផល។

ក.៦_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមដាននិងត្រួតពិនិត្យសមាសភាពចង្រៃនិងកត្តាអវិជ្ជមានដទៃទៀតដែលប៉ះពាល់ដល់ផលិតកម្មដំឡូងមី។ កត្តាគំរាមកំហែងនិងហានិភ័យត្រូវគ្រប់គ្រងនិងទប់ស្កាត់ តាមរយៈវិធានការដ៏មានប្រសិទ្ធភាពដើម្បីចៀសវាងការខាតបង់ផ្នែកសេដ្ឋកិច្ច។ ក្រសួងត្រូវផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងសមាសភាពចង្រៃឱ្យបានទូលំទូលាយនិងទាន់ពេលវេលាដល់កសិករ អ្នកកែច្នៃ និងអ្នកពាក់ព័ន្ធទាំងអស់តាមរយៈប្រព័ន្ធផ្សព្វផ្សាយដែលមានប្រសិទ្ធភាព។

ក.៧_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវផ្តល់សៅផ្សព្វផ្សាយគោលការណ៍ផលិតកម្មដំឡូងមីវៃឆ្លាត(អនុវត្តតាមបច្ចេកទេស) ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុនិងការអនុវត្តកសិកម្មល្អដល់កសិករ។ ក្រសួងត្រូវស្វែងរក ធ្វើការពិសោធ និងផ្សព្វផ្សាយបច្ចេកវិទ្យានិងបច្ចេកទេសថ្មីដែលមានតម្លៃទាបនិងសមស្របសម្រាប់កសិករដើម្បីបង្កើនផលិតភាពផលិតកម្មដំឡូងមីរបស់ពួកគេ។

ក.៨_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបន្តលើកកម្ពស់បណ្តុះបណ្តាលបច្ចេកទេសដាំដុះដំណាំដំឡូងមីនិងអនុវត្តវិធានការកែលម្អគុណភាពដីកសិកម្មដូចជា ដាំដុះដំណាំគម្របដី ដាំដំណាំឆ្លាស់ ដាំដំណាំបង្វិល ដើម្បីធានានូវផលិតកម្មប្រកបដោយនិរន្តរភាព។

ក.៩_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវតែកែលម្អសេវាកម្មកសិកម្មឯកជន តាមរយៈការរៀបចំឱ្យមានសហគមន៍គ្រឿងយន្តឬឧបករណ៍កសិកម្ម(ផ្លូវការឬមិនផ្លូវការ) ដើម្បីបង្កើនផលិតភាពនិងគុណភាពសេវាកម្មរបស់ពួកគេ។ ក្រសួងត្រូវបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់កសិករដែលជាម្ចាស់គ្រឿងយន្តឬឧបករណ៍កសិកម្មទាំងនេះ ទាំងទ្រឹស្តីនិងការអនុវត្តផ្ទាល់នៅនឹងកន្លែង ដូច្នេះការងាររបស់ពួកគេនឹងអនុលោមតាមការអនុវត្តកសិកម្មប្រកបដោយនិរន្តរភាព វៃឆ្លាត និងបទដ្ឋានបច្ចេកទេស ដែលផ្តល់ទិន្នផលខ្ពស់និងតម្លៃសេវាអាចគ្រប់គ្រងបាន។

ក.១០_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវរៀបចំកសិករដាំដំឡូងមី ជាក្រុមផលិត ចង្កោមឬសហគមន៍ ហើយធ្វើសមាហរណកម្មសហគមន៍កសិកម្មទាំងនេះ ទៅក្នុងរចនាសម្ព័ន្ធប្រមូលផ្ដុំដែលស្របទៅនឹងតំបន់ទីតាំងភូមិសាស្ត្រ បរិបទសង្គម សេដ្ឋកិច្ច និងធន្ធះរបស់ពួកគេ។ រចនាសម្ព័ន្ធប្រមូលផ្ដុំនេះត្រូវបានគាំទ្រដោយការអភិវឌ្ឍស្ថាប័ននិងការកសាងសមត្ថភាព ដើម្បីធ្វើជាចំណុចតភ្ជាប់ជាមួយនឹងអ្នកពាក់ព័ន្ធ អ្នកផ្ដល់សេវាកម្មផ្សេងៗ និងវិស័យឯកជន តាមរយៈផលិតកម្មតាមកិច្ចសន្យា។

ក.១១_ នៅដើមរដូវកាលផលិតកម្មជារៀងរាល់ឆ្នាំ ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវសហការរៀបចំទិវាដំឡូងមីដើម្បីកំណត់ផែនការដាំដុះ កែច្នៃ និងនាំចេញ ផ្ដល់រង្វាន់លើកទឹកចិត្តដល់កសិករគំរូ រោងចក្រកែច្នៃ និងក្រុមហ៊ុននាំចេញឆ្នើម ហើយជាពិសេសគឺ ផ្សព្វផ្សាយបច្ចេកទេសនិងបច្ចេកវិទ្យាថ្មីៗដល់កសិករ។

***ខ_ ការអភិវឌ្ឍវិស័យឯកជនឱ្យកាន់តែរស់រវើក តាមរយៈការជួយរោងចក្រឧស្សាហកម្មកែច្នៃសម្រេចបាននូវទំហំសេដ្ឋកិច្ច(Economy of scale) និងការកាត់បន្ថយថ្លៃដើម ដើម្បីឱ្យពួកគេអាចប្រកួតប្រជែង ច្រៀតចូល និងក្ដោបក្ដាប់ចំណែកទីផ្សារបានដោយជោគជ័យ៖***

ខ.១_ ក្រសួងពាណិជ្ជកម្មត្រូវវិភាគនិងធ្វើបច្ចុប្បន្នភាពខ្សែច្រវាក់តម្លៃដំឡូងមីជាទៀងទាត់ ដោយពិនិត្យមើលនិន្នាការទីផ្សារ ការប្រកួតប្រជែងក្នុងតំបន់ និងរចនាសម្ព័ន្ធថ្លៃដើមនៅកម្ពុជា។ ការសិក្សានេះផ្ដល់ធាតុចូលផ្អែកលើភស្តុតាងសម្រាប់កិច្ចពិភាក្សាគោលនយោបាយ។ ដូច្នេះ វិធានការគោលនយោបាយអាចត្រូវកែសម្រួលឬបន្ថែមដោយក្រសួងឬស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការអភិវឌ្ឍវិស័យនេះប្រកបដោយសង្គតិភាពនិងបរិយាបន្ន ព្រមទាំងសម្រេចបាននូវគោលដៅដែលកំណត់ក្នុងគោលនយោបាយ។

ខ.២_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបង្កើតយុទ្ធសាស្ត្រទាក់ទាញវិនិយោគលើការកែច្នៃដំឡូងមី និងអនុវត្តផែនការសកម្មភាពរបស់ខ្លួនដើម្បីទាក់ទាញវិនិយោគិន ដូច្នេះសមត្ថភាពកែច្នៃដំឡូងមី ត្រូវបានបង្កើនគ្រប់គ្រាន់ដើម្បីសម្រេចគោលដៅនាំចេញដែលបានកំណត់ក្នុងគោលនយោបាយនេះ។ សៀវភៅកម្រងនីតិវិធីវិនិយោគនិងសេចក្ដីណែនាំអំពីការវិនិយោគក្នុងឧស្សាហកម្មកែច្នៃដំឡូងមី នឹងរៀបចំឱ្យបានរួចរាល់ ផ្សព្វផ្សាយ បង្ហោះលើគេហទំព័រ និងចែកជូនដល់ក្រុមវិនិយោគិនគោលដៅ។

ខ.៣_ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវផ្ដល់ការលើកទឹកចិត្តដូចជាការលើកលែងឬកាត់បន្ថយពន្ធលើប្រាក់ចំណេញ ពន្ធលើផលិតផលដែលកែច្នៃពីដំឡូងមី និងអាករលើតម្លៃបន្ថែមជូនដល់ប្រតិបត្តិករដំឡូងមីស្របច្បាប់ដែលសកម្មភាពអាជីវកម្មរបស់ពួកគេបានផ្ដល់ផលប្រយោជន៍ដោយផ្ទាល់ដល់កសិករ។

ខ.៤_ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម ត្រូវបង្កើតកញ្ចប់ថវិកាពិសេសសម្រាប់ធ្វើអន្តរាគមន៍នៅពេលដែលការប្រមូលផលរបស់កសិករលើសលប់ បង្កើតបានជាវិបត្តិដំឡូងមីជន់ ការបិទច្រកព្រំដែនជាបណ្ដោះអាសន្នរបស់ប្រទេសជិតខាង ទីផ្សារអន្តរជាតិមានភាពអាក់រអួល កត្តាគ្រោះធម្មជាតិ និងហេតុការណ៍ផ្សេងៗដែលកើតជាយថាហេតុ ដើម្បីសម្រួលដល់ការលំបាករបស់កសិករនិងរោងចក្រកែច្នៃ។

ខ.៥_ ក្រសួងរ៉ែនិងថាមពលនឹងបន្តគិតគូរព្រមទាំងអនុវត្តគោលនយោបាយបន្ថយថ្លៃលក់អគ្គិសនីជូនដល់អ្នកប្រើប្រាស់អគ្គិសនីសម្រាប់វិស័យឧស្សាហកម្ម ដែលក្នុងនោះមានទាំងឧស្សាហកម្មកែច្នៃដំឡូងមីនិងឧស្សាហកម្មប្រភេទផ្សេងៗទៀត ដោយពុំមានការរើសអើង។ ក្រសួងរ៉ែនិងថាមពលលើកទឹកចិត្តឱ្យរោងចក្រឧស្សាហកម្មកែច្នៃដំឡូងមី ធ្វើការផលិតអគ្គិសនីដើម្បីបម្រើសេចក្ដីត្រូវការរបស់រោងចក្រដំឡូងមីផ្ទាល់។ ចំពោះករណីសល់អគ្គិសនីពី

ការប្រើប្រាស់រួច រោងចក្រដំឡូងមីអាចធ្វើការចរចាលក់អគ្គិសនីនេះជូនអគ្គិសនីកម្ពុជា ដោយឈរលើមូលដ្ឋាននៃសេចក្តីត្រូវការអគ្គិសនីជាក់ស្តែង និងលក្ខខណ្ឌបច្ចេកទេសនៃការភ្ជាប់អគ្គិសនី និងថ្លៃអគ្គិសនី។ ករណីនេះ រោងចក្រឧស្សាហកម្មអាចដាក់ពាក្យស្នើសុំមកក្រសួងរ៉ែនិងថាមពល ដើម្បីក្រសួងធ្វើការពិនិត្យលើករណីជាក់ស្តែងនីមួយៗ។

ខ.៦_ ក្រសួងបរិស្ថាន ដោយមានការសហការពីក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវជួយជំរុញនិងសម្របសម្រួលកិច្ចដំណើរការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមសម្រាប់គម្រោងកែច្នៃដំឡូងមី ដើម្បីធានាថា វិធានការដែលបានកំណត់ក្នុងរបាយការណ៍នោះគឺអាចឆ្លើយតបទៅនឹងបញ្ហាប្រឈមលើការគ្រប់គ្រងសំណល់ បញ្ហាបំពុលបរិស្ថាននានា និងការប៉ះពាល់ដល់សុខភាពឬការរស់នៅរបស់ប្រជាពលរដ្ឋដែលរស់នៅជុំវិញទីតាំងកែច្នៃ ឬដែលអាស្រ័យនឹងប្រភពទឹកនៅផ្នែកខាងក្រោម។

ខ.៧_ ក្រសួងបរិស្ថានសហការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងស្ថាប័នពាក់ព័ន្ធ ជួយដល់ម្ចាស់រោងចក្រកែច្នៃដំឡូងមី តាមរយៈការផ្តល់ប្រឹក្សាបច្ចេកទេសឬបច្ចេកវិទ្យាសមរម្យនិងប្រកបដោយប្រសិទ្ធភាព ក្នុងការគ្រប់គ្រងការបំពុលបរិស្ថានដែលកើតចេញពីការកែច្នៃ ដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានឱ្យនៅកម្រិតអប្បបរមាលើសហគមន៍អេកូឡូស៊ីនិងជីវៈចម្រុះ និងបង្កើនតម្លៃបន្ថែមពីការប្រើប្រាស់សំណល់ពីផលិតកម្មកែច្នៃដំឡូងមី។ ក្រសួងបរិស្ថានត្រូវកំណត់នីតិវិធីនិងគោលការណ៍ណែនាំច្បាស់លាស់ ស្តីពីការជ្រើសរើសទីតាំងកែច្នៃដំឡូងមី ដើម្បីធានាថាទីតាំងកែច្នៃទាំងនោះមិនស្ថិតនៅក្នុងតំបន់លំនៅឋាន ទីប្រជុំជន ដែនជម្រកសត្វព្រៃ តំបន់ការពារ និង/ឬ តំបន់ងាយរងគ្រោះ។

ខ.៨_ ក្រសួងពាណិជ្ជកម្មត្រូវរៀបចំសម្របសម្រួលបង្កើតសមាគមឬសហព័ន្ធពាណិជ្ជកម្មដំឡូងមីជាតិមួយ ដើម្បីប្រមូលផ្តុំវិស័យឯកជន រួមមានអ្នកនាំចេញ អ្នកកែច្នៃ និងប្រតិបត្តិករពាក់ព័ន្ធក្នុងអាជីវកម្មដំឡូងមី និងណែនាំឱ្យស្ថាប័នដែលបានបង្កើតថ្មីនេះទៅចុះបញ្ជីនៅក្រសួងមហាផ្ទៃ ដើម្បីទទួលបានភាពស្របច្បាប់។

ខ.៩_ ក្រសួងពាណិជ្ជកម្មត្រូវរៀបចំវេទិកាធុរកិច្ចស្តីពីដំឡូងមី ដើម្បីលើកកម្ពស់ផលិតផលកែច្នៃពីដំឡូងមីរបស់កម្ពុជានិងផ្សារភ្ជាប់វិស័យឯកជនទៅនឹងបណ្តាញធុរកិច្ចអន្តរជាតិ យ៉ាងហោចណាស់២ឆ្នាំម្តង។

ខ.១០_ ក្រសួងពាណិជ្ជកម្មត្រូវបង្កើតប្រព័ន្ធប្រតិបត្តិការធុរកិច្ចអនឡាញ ដើម្បីភ្ជាប់វិស័យឯកជនកម្ពុជាជាមួយនឹងអ្នកទិញបរទេស ដូចជាគេហទំព័រដើម្បីចែករំលែកព័ត៌មានដំឡូងមី។ គេហទំព័រនេះអាចប្រគល់ឱ្យសមាគមដំឡូងមីគ្រប់គ្រងនិងដំណើរការ។

ខ.១១_ ក្រសួងពាណិជ្ជកម្មត្រូវចរចាជាមួយតំណាងរដ្ឋាភិបាលនៃប្រទេសគោលដៅនាំចេញនានា លើការលើកលែងពន្ធឬការកាត់បន្ថយពន្ធនិងកិច្ចសម្រួលពាណិជ្ជកម្ម ដើម្បីធ្វើឱ្យការនាំចេញពីកម្ពុជាមានដំណើរការដោយរលូន។ ក្រសួងពាណិជ្ជកម្មត្រូវជួយសម្របសម្រួលកិច្ចព្រមព្រៀងទិញ-លក់ផងដែរ ប្រសិនបើកិច្ចព្រមព្រៀងឬធានានៅកម្រិតរដ្ឋាភិបាលនិងរដ្ឋាភិបាលតម្រូវឱ្យមាន។

ខ.១២_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចរចាជាមួយតំណាងរដ្ឋាភិបាលនៃប្រទេសគោលដៅនាំចេញដើម្បីសម្រួលរបាំងអនាម័យនិងភូតគាមអនាម័យ និងរៀបចំពិធីសារអនាម័យនិងភូតគាមអនាម័យ បើត្រូវការឱ្យមាន។ ក្រសួងផ្តល់ការគាំទ្របច្ចេកទេសនិងកសាងសមត្ថភាពអ្នកនាំចេញកម្ពុជានិងភាគីពាក់ព័ន្ធឱ្យអាចបំពេញតាមអនុលោមភាពនៃអនាម័យនិងភូតគាមអនាម័យ។ សេវាអនាម័យនិងភូតគាមអនាម័យ ត្រូវពង្រឹងនិងពង្រីកបន្ថែមផ្អែកលើបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលើកទឹកចិត្តនិងបើកចំហដល់វិស័យឯកជនក្នុងការចូលរួមផ្តល់សេវានិងប្រព្រឹត្តិកម្មភូតគាមអនាម័យ។

ខ.១៣_ វិទ្យាស្ថានស្តង់ដាកម្ពុជានៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ត្រូវរៀបចំនិងធ្វើបច្ចុប្បន្នភាពស្តង់ដាផលិតផលតាមតម្រូវការទីផ្សារក្នុងស្រុកនិងប្រទេសនាំចូល ដើម្បីលើកកម្ពស់ផលិតផល

កែច្នៃពីដំឡូងមីរបស់កម្ពុជា និងផ្តល់ការគាំទ្របច្ចេកទេសនិងកសាងសមត្ថភាពដល់អ្នកកែច្នៃដំឡូងមី ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់គុណភាព នានាដែលចាំបាច់។

ខ.១៤_ ធនាគារជាតិនៃកម្ពុជាគួរតែពិនិត្យគម្រោងកម្ចីហិរញ្ញវត្ថុបច្ចុប្បន្ន(ប្រាក់កម្ចី) ដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឬធនាគារពាណិជ្ជកំពុងផ្តល់ឱ្យកសិករនិងវិស័យឯកជន។ ការត្រួតពិនិត្យគ្រោងការហិរញ្ញវត្ថុនេះ គឺដើម្បីកំណត់បញ្ហានិងច្នៃប្រឌិតគ្រោងការណ៍ថ្មីឱ្យស្របទៅនឹងជីវភាពរបស់កសិករ ប្រតិទិនដាំដុះដំឡូងមី និងកសាងសមត្ថភាពក្នុងការប្រើប្រាស់ប្រាក់កម្ចីប្រកបដោយប្រសិទ្ធភាព។

***គ_ ហេដ្ឋារចនាសម្ព័ន្ធត្រូវបានបង្កើតឡើងដើម្បីធ្វើឱ្យប្រព័ន្ធខ្សែច្រវាក់តម្លៃដំឡូងមីបំពេញមុខងារស្របតាមក្របខ័ណ្ឌផលិតកម្មផ្អែកលើទីផ្សារនិងផ្សារភ្ជាប់ជាមួយនឹងវិស័យពាក់ព័ន្ធ ក្នុងការបង្កើតបណ្តាញសេដ្ឋកិច្ចមូលដ្ឋានដ៏សកម្មដែលតម្លៃបន្ថែមត្រូវបានបង្កើននិងបែងចែកទៅជនបទ៖***

គ.១_ ក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានផលិតកម្មដំឡូងមីនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន គួរពិនិត្យលទ្ធភាពក្នុងការដាក់បញ្ចូលដំឡូងមីក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍និងផែនការវិនិយោគរបស់ខ្លួន ព្រមទាំងសហការជាមួយសហគមន៍មូលដ្ឋាន ដើម្បីប្រមូលផ្តុំមូលនិធិបដិភាគតាមលទ្ធភាពសម្រាប់ស្ថាបនានិងកែលម្អផ្លូវចូលទៅកាន់ចម្ការឱ្យបានគ្រប់រដូវ។

គ.២_ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវផ្តល់ការគាំទ្រតាមរយៈការលើកទឹកចិត្តដែលចាំបាច់ដល់វិស័យឯកជនក្នុងការកសាងឃ្លាំងស្តុកទុកជាធនាគារដំឡូងមី ឬមជ្ឈមណ្ឌលពហុបំណងនៅទីតាំងយុទ្ធសាស្ត្រសំខាន់ៗសម្រាប់គ្រប់គ្រងការប្រមូលផលនិងស្តុកទុកផលិតផលដំឡូងមីកែច្នៃ។

គ.៣_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសហការជាមួយក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងបរិស្ថាន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធចាំបាច់ រួមមានអាងស្តុកទឹក អណ្តូងទឹក ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធស្រោចស្រពជាដើម។

គ.៤_ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្មត្រូវបន្តសហការជាមួយប្រទេសជិតខាង ដើម្បីបង្កើតកិច្ចព្រមព្រៀង កំណត់នីតិវិធី និងបែបបទនានាស្តីពីការដឹកជញ្ជូនទំនិញឆ្លងកាត់ ជាពិសេសផលិតផលដំឡូងមីឆ្ពោះទៅកាន់កំពង់ផែនៃប្រទេសជិតខាងឱ្យបានច្បាស់លាស់។

គ.៥_ ក្រសួងសាធារណការនិងដឹកជញ្ជូនបន្តស្តារសាងសង់ផ្លូវថ្នល់ ផ្លូវដែក ព្រមទាំងជំរុញការតភ្ជាប់ទៅរោងចក្រសហគ្រាសនិងតំបន់សេដ្ឋកិច្ចពិសេស។ ក្រសួងត្រូវធ្វើអន្តរាគមន៍ក្នុងការកំណត់ថ្លៃពិសេសក្នុងករណីចាំបាច់សម្រាប់ការដឹកជញ្ជូនផលិតផលដំឡូងមី ដើម្បីចូលរួមចំណែកដល់ការកាត់បន្ថយថ្លៃដើមផលិតផលកែច្នៃពីដំឡូងមី។

គ.៦_ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ (កំពង់ផែ និងអាជ្ញាធរមានសមត្ថកិច្ចប្រចាំការនៅមាត់ច្រក) ត្រូវកំណត់នីតិវិធីចាំបាច់ក្នុងការផ្តល់ការអនុគ្រោះពិសេសចំពោះផលិតផលដំឡូងមី នៅពេលដែលផលិតផលទាំងនេះទៅដល់កំពង់ផែនិងច្រកនាំចេញ ដូចជាការកាត់បន្ថយកម្រៃសេវាគ្រប់ប្រភេទ ការបំពេញបែបបទភ្លាមៗ ការផ្តល់ឃ្លាំងស្តុកទុក ឧបករណ៍លើកដាក់ទំនិញជាដើម ដូចសិទ្ធិពិសេសដែលបានផ្តល់ដល់ការនាំចេញអង្ករ។

គ.៧_ ក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចូលរួមសហការទប់ស្កាត់រាល់សកម្មភាពល្មើសវិស័យដំឡូងមី និងដោះស្រាយវិវាទក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដូចជាការប្រកប

អាជីវកម្ម-ពាណិជ្ជកម្មមិនត្រឹមត្រូវ ការក្លែងបន្លំគុណភាព ការឆបោក ការបង្កការលំបាកក្នុងការទិញលក់ ការយកកម្រៃក្រៅផ្លូវការ។ល។

គ.៨_ ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតាមដាននិងត្រួតពិនិត្យឱ្យបានដិតដល់លើការអនុវត្តផែនការទប់ស្កាត់ការបំពុលបរិស្ថានឬផែនការគ្រប់គ្រងបរិស្ថាន ដែលបានកំណត់និងអនុម័តក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ឬកិច្ចសន្យាការពារបរិស្ថានរបស់រោងចក្រកែច្នៃនិងឃ្លាំងប្រមូលទិញដំឡូងមី ដើម្បីធានាបានការបង្ការនិងទប់ស្កាត់ហានិភ័យបំពុលដល់ធនធានបរិស្ថានឬការប៉ះពាល់ដល់សង្គម។

គ.៩_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបង្កើនផលិតភាពផលិតកម្មនិងការពារសុវត្ថិភាពរបស់កសិករនិងកម្មករនៅជនបទ តាមរយៈការបណ្តុះបណ្តាលទាំងទ្រឹស្តីនិងការអនុវត្ត ដើម្បីកែលម្អគុណភាពសេវានិងការអនុវត្តបច្ចេកទេសកសិកម្មល្អឱ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាពនៅក្នុងវិស័យដំឡូងមី។

### **៥.៦.២_ គម្រោងរយៈពេល១០ឆ្នាំ**

***ការបង្កើនភាពប្រកួតប្រជែងនៃវិស័យនេះត្រូវអនុវត្តក្នុងទម្រង់ភាពជាដៃគូរវាងរដ្ឋនិងឯកជន ដើម្បីលើកកម្ពស់វិស័យនេះទៅជាឧស្សាហកម្មកែច្នៃផលិតផលសម្រេចមានតម្លៃបន្ថែមច្រើន៖***

ក_ ក្រសួងពាណិជ្ជកម្មត្រូវសហការជាមួយវិស័យឯកជន ដើម្បីសិក្សាទីផ្សារកសិផល តាមដានទីផ្សារ និងផ្តល់នូវធាតុចូលយុទ្ធសាស្ត្រដល់គណៈកម្មាធិការតម្រង់ទិស ហើយរួមសហការជាមួយក្រសួងពាក់ព័ន្ធនិងតួអង្គខ្សែច្រវាក់តម្លៃ ដើម្បីបង្កើតផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍវិស័យនេះក្នុងរយៈពេលវែង។

ខ_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវសហការជាមួយភាគីពាក់ព័ន្ធនិងបណ្តាប្រទេសនានាក្នុងតំបន់ដើម្បីលើកកម្ពស់ការងារស្រាវជ្រាវនិងអភិវឌ្ឍន៍ដំណាំដំឡូងមី ក្នុងគោលបំណងកែលម្អនិងធានាឱ្យបាននូវផលិតកម្មដំឡូងមីប្រកបដោយនិរន្តរភាព ជាពិសេសបង្កាត់ពូជដំឡូងមីថ្មីដែលស្របតាមអេកូឡូស៊ីកសិកម្មនៅកម្ពុជានិងឆ្លើយតបទៅនឹងតម្រូវការទីផ្សារគោលដៅ ព្រមទាំងស្រាវជ្រាវបង្កើតនវានុវត្តន៍ថ្មីដើម្បីកាត់បន្ថយថ្លៃដើមផលិតកម្មនិងបង្កើនផលិតភាពដំឡូងមី។

គ_ ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងស្ថាប័នពាក់ព័ន្ធត្រូវសហការជាមួយវិស័យឯកជន ជំរុញឱ្យមានការស្រាវជ្រាវ នវានុវត្តន៍ និងអភិវឌ្ឍន៍បង្កើតផលិតផលថ្មីៗចេញពីដំឡូងមីដោយប្រើប្រាស់នូវលក្ខណៈពិសេសរបស់ដំឡូងមីឱ្យអស់លទ្ធភាព ដើម្បីបង្កើនឧត្តមភាពប្រកួតប្រជែងក្នុងទីផ្សារ។ លទ្ធផលពីការស្រាវជ្រាវត្រូវផ្ទេរទៅឱ្យវិស័យឯកជនយកទៅធ្វើអាជីវកម្ម ដោយមានការចុះបញ្ជីកម្មសិទ្ធិបញ្ញាស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ឃ_ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ និងរដ្ឋបាលថ្នាក់ក្រោមជាតិបន្តស្តារពង្រីកនិងសាងសង់ផ្លូវកាត់យុទ្ធសាស្ត្រ ដើម្បីភ្ជាប់តំបន់អភិវឌ្ឍឧស្សាហកម្ម កសិកម្ម កសិ-ឧស្សាហកម្ម ទីតាំងកែច្នៃទៅកំពង់ផែក្នុងស្រុកនិងច្រកនាំចេញ ក្នុងគោលដៅកាត់បន្ថយពេលវេលានិងថ្លៃដឹកជញ្ជូន។

ង_ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងវិស័យឯកជនសហការធ្វើទំនើបកម្មសេវាកម្មនិងពិនិត្យលទ្ធភាពក្នុងការពង្រីកវិសាលភាពនិងសមត្ថភាពកំពង់ផែដែលមានស្រាប់ និងបង្កើតកំពង់ផែក្នុងស្រុកថ្មីៗបន្ថែមទៀត ដើម្បីសម្រួលការដឹកជញ្ជូនកសិផលនិងផលិតផលកែច្នៃបានលឿន ចំណាយតិច បានបរិមាណច្រើន សំដៅបង្កើនសមត្ថភាពប្រកួតប្រជែងនិងកាត់បន្ថយថ្លៃផលិតផលដែលនាំចេញពីកម្ពុជា។

ច_ ក្រសួងរ៉ែនិងថាមពល ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងក្រសួងពាក់ព័ន្ធត្រូវធ្វើការវាយតម្លៃផលចំណេញសេដ្ឋកិច្ចពីការលាយអេតាណុលដែលផលិតពីដំឡូងមីជាមួយនឹងប្រេងសាំង។ ការលាយអេតាណុលនេះ អាចនឹងកាត់បន្ថយការនាំចូលប្រេងសាំងក្នុងបរិមាណមួយនិងជួយឱ្យរោងចក្រអេតាណុលក្នុងស្រុកមានដំណើរការកាន់តែសកម្ម។ តាមរយៈការរៀនសូត្រពីបទពិសោធជាសកល ដើម្បីទទួលបានការគាំទ្រពីអតិថិជន ល្បាយអេតាណុលនឹងប្រេងសាំងនេះ(Gasohol) ត្រូវមានតម្លៃទាបជាងប្រេងសាំង ហើយធ្វើឱ្យម៉ាស៊ីនដំណើរការបានល្អ។ គោលនយោបាយអេតាណុលដែលផលិតពីដំឡូងមីត្រូវបង្កើតឡើង ប្រសិនបើការសិក្សារកឃើញថា ផ្តល់ផលប្រយោជន៍ច្រើនដល់សេដ្ឋកិច្ចជាតិ វិស័យឯកជនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់អេតាណុល ហើយប្រេងឥន្ធនៈថ្មីនេះទទួលបានការគាំទ្រពីភ្នាក់ងារទីផ្សារនិងអ្នកប្រើប្រាស់។

ឆ_ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងស្ថាប័នពាក់ព័ន្ធត្រូវសិក្សាពីផលចំណេញសេដ្ឋកិច្ចនិងលើកទឹកចិត្តជំរុញឱ្យវិស័យឯកជនបង្កើតតំបន់ពិសេសកែច្នៃដំឡូងមី ដែលអាចជាគំរូសម្រាប់កសិផលផ្សេងទៀត។ គោលគំនិតនេះ គឺដើម្បីបង្កើតតំបន់មួយដែលព័ទ្ធជុំវិញដោយចម្ការដំឡូងមីជាខ្សែក្រវាត់សម្រាប់ផ្គត់ផ្គង់ដំឡូងមីដល់រោងចក្រកែច្នៃជាច្រើនក្នុងទីតាំងតែមួយ។ ដំណើរការនេះមានភាពសាមញ្ញដោយកសិករលក់មើមស្រស់ដល់រោងចក្រកែច្នៃម្សៅមី ហើយរោងចក្រកែច្នៃម្សៅទៅជាផលិតផលពាក់កណ្តាលសម្រេចនិងសម្រេច។ ការបង្កើតតំបន់កែច្នៃពិសេសនេះអាចបង្កើតតម្លៃបន្ថែមច្រើនដល់សេដ្ឋកិច្ចជនបទក្នុងទម្រង់ផ្សេងៗ ហើយការគ្រប់គ្រងការបំពុលបរិស្ថាននៅនឹងកន្លែងតែមួយមានភាពងាយស្រួល។ តំបន់ពិសេសនេះអាចធ្វើឱ្យថ្លៃដើមផលិតផលទាប ព្រោះថាថាមពលបានមកពីសំណល់ដំឡូងមីអាចធ្វើជាអគ្គិសនីសម្រាប់ដំណើរការរោងចក្រឧស្សាហកម្មទាំងអស់។ តួអង្គពាក់ព័ន្ធស្ថិតនៅជិតគ្នា ដែលអាចសន្សំចំណាយលើការដឹកជញ្ជូនវត្ថុធាតុដើមទៅកាន់កន្លែងកែច្នៃខុសៗគ្នា។

ជ_ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវសិក្សាពីផលចំណេញនៃការប្រើប្រាស់ដំឡូងមីរួមផ្សំនឹងគ្រាប់ធញ្ញជាតិផ្សេងៗទៀតសម្រាប់ផលិតចំណីសត្វដែលមានតម្លៃថោកនិងមានគុណប្រយោជន៍ច្រើនដល់ការរីកលូតលាស់ ផលិតភាព និងសុខភាពរបស់សត្វ។ ដំឡូងមី ក្រៅពីផ្តល់ផលដល់កសិករដែលដាំវា ក៏អាចរួមចំណែកលើកស្ទួយជីវភាពកសិករផ្សេងទៀត តាមរយៈការផ្សារភ្ជាប់ការដាំដំឡូងមីនិងការចិញ្ចឹមសត្វ ដែលជាចំណុចគន្លឹះដ៏សំខាន់មួយក្នុងការអភិវឌ្ឍផលិតកម្មសត្វប្រកបដោយសក្តានុភាពនិងប្រសិទ្ធភាពខ្ពស់នៅកម្ពុជា។

## ៥.៧_ ការគ្រប់គ្រងហានិភ័យ

ដំឡូងមីត្រូវបានគេនិយាយតៗគ្នាថា ជាដំណាំដែលធ្វើឱ្យបាត់បង់ជីជាតិដី។ តាមពិត ដូចដំណាំដទៃទៀតដែរ ដំឡូងមីស្រូបយកសារធាតុចិញ្ចឹមច្រើនដើម្បីផលិតទិន្នផលខ្ពស់ ដូច្នេះការបាត់បង់ជីជាតិដីបណ្តាលមកពីការដាំដំណាំតែមួយប្រភេទក្នុងរយៈពេលយូរ និងការអនុវត្តក្បេត្រសាស្ត្រមិនត្រឹមត្រូវ។ គុណភាពដីនិងជីជាតិដីត្រូវតែរក្សាឱ្យបានតាមរយៈការប្រើប្រាស់ដីប្រកបដោយនិរន្តរភាពនិងការអនុវត្តកសិកម្មឆ្លាតវៃ។ ប្រព័ន្ធសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មទូលំទូលាយត្រូវបង្កើតឡើង ដើម្បីលើកកម្ពស់ការយល់ដឹងនិងលើកទឹកចិត្តដល់កសិករដាំដំឡូងមីឱ្យប្រើប្រាស់ដីស្របតាមគោលការណ៍និរន្តរភាពនិងបច្ចេកទេស។

ប្រទេសកម្ពុជានិងតំបន់អាស៊ីអាគ្នេយ៍ក្នុងរយៈពេលចុងក្រោយនេះ បានរងនូវផលប៉ះពាល់ដោយកត្តាចង្រៃលើដំណាំដំឡូងមី ដូចជា ចៃម្សៅនិងពីងពាង ជំងឺរួញស្លឹកម៉ូសាអ៊ិក និងជំងឺអំបោសធ្មប់ ដែលបង្កឡើងដោយវីរុសនិងបាក់តេរី។ល។ ដូច្នេះ ការគំរាមកំហែងដែលកំពុងកើតមានឡើងត្រូវគ្រប់គ្រងឱ្យបានហ្មត់ចត់និងទប់ស្កាត់ឱ្យបាន

ទាន់ពេលវេលា ដើម្បីបញ្ចៀសការរីករាលដាលទ្រង់ទ្រាយធំដែលមិនអាចគ្រប់គ្រងនិងមិនអាចបញ្ឈប់បាននៅដំណាក់កាលចុងក្រោយ ដែលនាំមកនូវការខាតបង់សេដ្ឋកិច្ចធ្ងន់ធ្ងរនាពេលបច្ចុប្បន្ននិងអនាគត។ កម្ពុជាត្រូវសហការជាមួយបណ្ដាប្រទេសក្នុងតំបន់និងវិទ្យាស្ថានស្រាវជ្រាវនានាក្នុងពិភពលោក ដើម្បីកាត់បន្ថយនិងគ្រប់គ្រងការគំរាមកំហែងពីហានិភ័យទាំងនេះ។

ការប្រើប្រាស់ថ្នាំកសិកម្មនិងជីគីមីនៅក្នុងការដាំដុះដំឡូងមីរបស់កសិករ ដែលមានការយល់ដឹងតិចតួចអំពីបទដ្ឋានបច្ចេកទេសនៃការប្រើថ្នាំ និងជី និងវិធានការការពារសុវត្ថិភាពបរិស្ថាន អាចបណ្ដាលជាហានិភ័យប៉ះពាល់ដល់ជីវៈចម្រុះ បរិស្ថានដីនិងទឹក ដូចនេះចាំបាច់ត្រូវមានការយកចិត្តទុកដាក់ខ្ពស់និងដាក់ជាវិធានការសមស្របនិងមានប្រសិទ្ធភាព។ ស្ថាប័នពាក់ព័ន្ធត្រូវផ្ដល់ព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយដល់សហគ្រាស ក្រុមហ៊ុន និងកសិករដាំដុះដំឡូងមីអំពីការប្រើប្រាស់ថ្នាំនិងជីឱ្យបានត្រឹមត្រូវនិងមានផែនការគ្រប់គ្រងហានិភ័យច្បាស់លាស់ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន ដែលអាចកើតចេញជាយថាហេតុពីការប្រើប្រាស់ថ្នាំនិងជីដោយខុសបច្ចេកទេស។

តម្លៃដំឡូងមីមានការប្រែប្រួលមិនទៀងទាត់និងពិបាកក្នុងការព្យាករ។ តម្លៃនេះទទួលរងនូវឥទ្ធិពលដោយផ្ទាល់ពីបរិមាណតម្រូវការនិងលទ្ធភាពផ្គត់ផ្គង់ដំឡូងមី ដំណាំឬផលិតផលដែលអាចជំនួសបាន និងគោលនយោបាយរបស់ប្រទេសនាំចូល។ ផលិតកម្មដំឡូងមីនៅកម្ពុជាមិនអាចគ្រប់គ្រងបាននិងមានភាពផុយស្រួយ ដោយសារកសិករងាយនឹងផ្លាស់ប្ដូរទៅដាំដំណាំផ្សេងទៀតដែលពួកគេរំពឹងទុកថា ទទួលបានតម្លៃខ្ពស់ជាងដំឡូងមី។ ដូច្នេះ ដំឡូងមីត្រូវធ្វើឱ្យក្លាយជាដំណាំយុទ្ធសាស្ត្រដែលផ្ដល់ផលចំណេញដល់កសិករ ខណៈពេលដែលទីផ្សារត្រូវបានធានាដល់ពួកគេតាមរយៈផលិតកម្មកសិកម្មតាមកិច្ចសន្យាឬយន្តការផ្សេងៗ។

ការលើកកម្ពស់ការនាំចេញផលិតផលកែច្នៃពីដំឡូងមីដោយផ្ទាល់ពីប្រទេសកម្ពុជា ប្រឈមនឹងការប្រកួតប្រជែងយ៉ាងខ្លាំងពីប្រទេសជិតខាងដែលបានក្ដោបក្ដាប់ផលិតកម្មដំឡូងមីក្នុងស្រុកនិងទីផ្សារពិភពលោកអស់រយៈពេលជាយូរមកហើយ។ ដោយមានឧត្ដមភាពប្រៀបផ្ដាច់ ប្រទេសជិតខាងខ្លះអាចកំណត់ឬទម្លាក់តម្លៃក្នុងកម្រិតមួយដែលធ្វើឱ្យការនាំចេញពីកម្ពុជាមិនអាចធ្វើទៅបានចំពោះផលិតផលដូចគ្នា។ សរុបមក ការលើកកម្ពស់ភាពប្រកួតប្រជែងពាណិជ្ជកម្ម តម្រូវឱ្យមានភាពជាដៃគូរវាងអ្នកផលិត វិស័យឯកជន និងវិស័យសាធារណៈ លើធនធានដែលមានត្រូវប្រើប្រាស់ជាយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពនិងមានការគាំទ្រដោយផ្ទាល់ពីរាជរដ្ឋាភិបាល។

ម្យ៉ាងវិញទៀត ផលិតផលដំឡូងមីរបស់កម្ពុជាត្រូវមានតម្លៃប្រហាក់ប្រហែលនិងគុណភាពដូចគ្នានឹងអ្នកនាំចេញបរទេស ព្រមទាំងមានលក្ខខណ្ឌពាណិជ្ជកម្មគួរឱ្យទាក់ទាញផងដែរ។ លក្ខខណ្ឌទាំងនេះធ្វើឱ្យវិស័យឯកជនកម្ពុជាប្រឈមនឹងការលំបាកដោយសារអាជីវកម្មរបស់ពួកគេភាគច្រើន មានលក្ខណៈគ្រួសារ មានទ្រង់ទ្រាយតូច ខ្វះជំនាញ ខ្វះដើមទុន គ្មានលទ្ធភាពធានាគុណភាពផលិតផលនិងបរិមាណផ្គត់ផ្គង់ ប្រើប្រាស់បច្ចេកវិទ្យា និងឧបករណ៍ហួសសម័យ។ ទន្ទឹមនឹងនេះ ការបង្កើនភាពប្រកួតប្រជែងពាណិជ្ជកម្ម ការធ្វើឱ្យសហគ្រាសធុនតូចនិងមធ្យមមានភាពប្រសើរឡើងនិងឈានដល់កម្រិតស្តង់ដាអាជីវកម្មអន្តរជាតិ ព្រមទាំងការទាក់ទាញការវិនិយោគទ្រង់ទ្រាយធំពីបរទេសគឺជាអាទិភាព។

ការកែច្នៃដំឡូងមីក៏អាចបង្កឱ្យមានហានិភ័យច្រើនទៅដល់ធនធានបរិស្ថានមានជាអាទិ៍ ការបំពុលទឹកដោយសារការបញ្ចេញសំណល់រាវក្នុងបរិមាណរាប់ពាន់ម៉ែត្រគូបក្នុងមួយថ្ងៃ រួមនឹងបញ្ហាក្លិនស្អុយខ្លាំងពីទឹកកខ្វក់ ភក់ល្បាប់

និងសំបកមើម។ នៅខណៈដែលហេដ្ឋារចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងសំណល់ឬទប់ស្កាត់ការបំពុលទាំងនៅលើទីតាំងកែច្នៃផ្ទាល់និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនៅមានកម្រិត ស្ថាប័នពាក់ព័ន្ធចាំបាច់ទាមទារឱ្យមានការរៀបចំកសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងការបំពុលបរិស្ថាន ស្របនឹងការដំឡើងរោងចក្រឱ្យរួចរាល់ក្នុងពេលដំណាលគ្នា។ រោងចក្រកែច្នៃទាំងអស់អាចស្ថិតក្នុងតំបន់កែច្នៃពិសេសមួយ ដើម្បីកាត់បន្ថយការចំណាយវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដោយការប្រើប្រាស់និងទប់ស្កាត់ការបំពុលរួមគ្នាពីប្រភពតែមួយ។ ស្ថាប័នពាក់ព័ន្ធត្រូវជំរុញនិងគាំទ្ររោងចក្រកែច្នៃឱ្យបំប្លែងសំណល់ដែលមាន ឱ្យទៅជាធនធានផលិតផលមានតម្លៃឬថាមពលដែលផ្តល់ប្រយោជន៍ត្រឡប់ដល់សហគមន៍កសិកម្ម រោងចក្រកែច្នៃម្សៅ និងឧស្សាហកម្មពាក់ព័ន្ធវិញ។ល។

## ៦. ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ

ដើម្បីអនុវត្តគោលនយោបាយជាតិដំឡូងមីឱ្យមានប្រសិទ្ធភាព ចាំបាច់ត្រូវមានប្រព័ន្ធត្រួតពិនិត្យ តាមដាន វាយតម្លៃ និងសំណើកែលម្អការអនុវត្ត ដោយផ្តោតលើ៖

- គោលដៅនិងយុទ្ធសាស្ត្រគោលនយោបាយជាតិដំឡូងមី
- សូចនាករនៃផែនការសកម្មភាពស្តីពីគោលនយោបាយជាតិដំឡូងមី
- របាយការណ៍វឌ្ឍនភាពនៃគោលនយោបាយជាតិដំឡូងមី
- លទ្ធផលដែលទទួលបានធៀបនឹងចំណុចគោលដៅ
- របាយការណ៍ពិនិត្យឡើងវិញលើការអនុវត្តគោលនយោបាយជាតិដំឡូងមី
- ផលប្រយោជន៍ដែលទទួលបានពីការអនុវត្តគោលនយោបាយជាតិដំឡូងមី

គណៈកម្មាធិការស្តីពីគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចក្នុងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃគោលនយោបាយ ដើម្បីធានាឱ្យមានសង្គតិភាពនិងតម្រែតម្រង់គោលនយោបាយ នេះឱ្យស្របគ្នាជាមួយគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធដទៃទៀត។

លេខាធិការដ្ឋាននៃក្រុមការងារដំឡូងមីត្រូវត្រួតពិនិត្យនិងវាយតម្លៃ អាចជាមន្ត្រីជាន់ខ្ពស់ឬមន្ត្រីជំនាញខាងត្រួតពិនិត្យនិងវាយតម្លៃនៃក្រសួង/ស្ថាប័នពាក់ព័ន្ធនីមួយៗ ដែលអាចចូលរួមក្នុងសកម្មភាពវាយតម្លៃ និងមានចំណេះដឹង និងបទពិសោធដែលអាចផ្តល់មតិកែលម្អបែបស្ថាបនានិងជាគុណូបលើផែនការយុទ្ធសាស្ត្រនិងសកម្មភាព។ លេខាធិការដ្ឋាននេះត្រូវរៀបចំផែនការមេមួយសម្រាប់ត្រួតពិនិត្យនិងវាយតម្លៃ កំណត់សូចនាករឱ្យបានច្បាស់លាស់ រួមទាំងវិធីសាស្ត្រស្រាវជ្រាវ យន្តការប្រមូលនិងវិភាគទិន្នន័យ និងឧបករណ៍ផ្ទៀងផ្ទាត់លទ្ធផលដែលសម្រេចបានពីការអនុវត្តគោលនយោបាយនេះ និងធ្វើរបាយការណ៍ទៀងទាត់ជូនប្រធានក្រុមការងារដំឡូងមី និងក្រសួង/ស្ថាប័នពាក់ព័ន្ធតាមការស្នើសុំនិងចាំបាច់។ ដោយមានការគាំទ្រពីក្រុមលេខាធិការដ្ឋាននៃក្រុមការងារដំឡូងមី អាចជ្រើសរើសទីប្រឹក្សាឬជំនាញការដើម្បីរៀបចំបង្កើតប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ ព្រមទាំងធ្វើសកម្មភាពតាមផែនការដែលជារបស់ខ្លួន។

## ៧. សេចក្តីសន្និដ្ឋាន

ការអនុវត្តដោយជោគជ័យលើគោលនយោបាយជាតិនេះបានធ្វើឱ្យដំឡូងមីក្លាយជាដំណាំយុទ្ធសាស្ត្រមួយដែលអាចផ្តល់ប្រាក់ចំណូលដល់កសិករនិងជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍកសិ-ឧស្សាហកម្មនៅព្រះរាជាណាចក្រកម្ពុជា

ដើម្បីឈានឡើងដល់ខ្សែច្រវាក់តម្លៃថ្មីដែលមានគុណប្រយោជន៍បន្ថែមច្រើន។ អាស្រ័យហេតុនេះ ការធ្វើពាណិជ្ជូបនីយកម្មនៃផលិតកម្មដំឡូងមីនិងការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្មត្រូវធ្វើឡើងក្នុងពេលតែមួយ ដើម្បីបង្កើនភាពប្រកួតប្រជែងជាមួយនឹងដំណាំដូចគ្នាឬដំណាំដែលអាចជំនួសគ្នាបាន ដែលកំពុងដាំដុះនិងកែច្នៃនៅតំបន់នានាក្នុងពិភពលោក។ ការកើនឡើងនៃផលិតភាពនិងឧត្តមភាពប្រកួតប្រជែងនេះ នឹងបង្កើនផលចំណេញដល់តួអង្គនីមួយៗក្នុងខ្សែច្រវាក់តម្លៃ និងជួយកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានដែលបង្កឡើងដោយការប្រែប្រួលតម្លៃដំឡូងមី។

ដោយមើលឃើញពីឧត្តមភាពប្រកួតប្រជែងនៃវិស័យនេះ គោលនយោបាយនេះកំណត់ចក្ខុវិស័យច្បាស់លាស់និងដាក់ចេញនូវគោលនយោបាយចាំបាច់នានាសម្រាប់អភិវឌ្ឍដំឡូងមី សំដៅជួយកសិករ រោងចក្រកែច្នៃ ក្រុមហ៊ុននាំចេញ និងប្រតិបត្តិករជាច្រើនទៀតកំពុងដំណើរការអាជីវកម្មនេះ។ ដូច្នេះ ការគាំទ្រតួអង្គដែលមានស្រាប់ ការទាក់ទាញការវិនិយោគបន្ថែម ការដោះស្រាយបញ្ហាប្រឈម ការកែលម្អបរិយាកាសអាជីវកម្មឱ្យកាន់តែល្អប្រសើរ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលឆ្លើយតបនឹងតម្រូវការរបស់ប្រតិបត្តិករ នឹងធ្វើឱ្យវិស័យនេះក្លាយជាកម្លាំងចលករដ៏សកម្មមួយទៀតរបស់សេដ្ឋកិច្ចជាតិ។

គោលនយោបាយនេះនឹងនាំមកនូវកំណើនសេដ្ឋកិច្ចបន្ថែមប្រកបដោយបរិយាបន្នដល់ប្រទេសកម្ពុជាក្នុងបរិបទប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប និងគាំទ្រដល់ផែនការរបស់រាជរដ្ឋាភិបាល ឆ្ពោះទៅកាន់ប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅពេលខាងមុខ។

# សទ្ទានុក្រម

**វាក្យសព្ទសំខាន់ៗដែលប្រើក្នុងគោលនយោបាយជាតិនេះត្រូវកំណត់និយមន័យដូចខាងក្រោម៖**

**កសិកម្មឆ្លាតវៃ**
(Smart Agriculture)
សំដៅដល់វិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យាដែលជួយដល់ការកែប្រែនិងរៀបចំប្រព័ន្ធកសិកម្មបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីធានានូវសន្តិសុខស្បៀង សុវត្ថិភាព និងធនធានបរិស្ថាន។

**កសិកម្មបែបប្រពៃណី**
(Traditional Agriculture)
សំដៅដល់របៀបធ្វើកសិកម្មតាមទម្លាប់ ប្រើប្រាស់ឧបករណ៍បុរាណ ពឹងផ្អែកខ្លាំងលើធម្មជាតិនិងជំនឿប្រពៃណី។

**ការចុះបញ្ជីអត្រាកំណើនប្រចាំឆ្នាំសរុប**
(Compound Annual Growth Rate CAGR)
សំដៅដល់អត្រានៃផលត្រឡប់ដែលគួរទទួលបានពីការវិនិយោគ ដែលកើនឡើងពីតុល្យភាពដើមគ្រាធៀបនឹងតុល្យភាពចុងគ្រា។

**ក្របខ័ណ្ឌអភិបាលកិច្ច**
(Governance Framework)
សំដៅដល់រចនាសម្ព័ន្ធដែលបង្កើតដោយរាជរដ្ឋាភិបាលដើម្បីប្រមូលផ្តុំស្ថាប័នភាគីឬតួអង្គពាក់ព័ន្ធមកធ្វើការសហការគ្នាប្រកបដោយសង្គតិភាពនៃសកម្មភាព ការបំពេញឱ្យគ្នាទៅវិញទៅមកតាមមុខងាររបស់ខ្លួន និងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចចក្ខុវិស័យរួម ដោយមានតម្លាភាព គណនេយ្យភាព ការគ្រប់គ្រងនិងដឹកនាំច្បាស់លាស់។

**ក្សេត្រសាស្ត្រ**
(Agronomy)
សំដៅដល់វិទ្យាសាស្ត្រគ្រប់គ្រងដីនិងការដាំដុះដំណាំ។

**ខ្សែក្រវាត់ដំឡូងមី( តំបន់ )**
(Cassava Belt)
សំដៅដល់តំបន់ដែលមានភូមិសាស្ត្រសមស្របសម្រាប់ការដាំដុះដំឡូងមី។

**ខ្សែច្រវាក់តម្លៃ**
(Value Chains)
សំដៅដល់បណ្តុំនៃសកម្មភាពដែលបានធ្វើដោយតួអង្គនីមួយៗតាំងពីផលិត កែច្នៃ នាំចេញ និងប្រើប្រាស់។

**ចំណិតដំឡូងមីក្រៀម**
(Dry Chip)
សំដៅដល់ចំណិតមើមដែលកាប់ជាដុំ ហើយសម្ងួតដោយកម្តៅថ្ងៃ តាមរយៈការហាលលើទីលានឬហាលលើស្បៃ។ វាមានទំហំឬប្រវែងទៅតាមការចង់បានរបស់អ្នកទិញ និងត្រូវកាប់ដោយដៃឬម៉ាស៊ីន។ ចំណិតដំឡូងក្រៀមមានសំបកប្រើសម្រាប់ការចម្រាញ់អេតាណុល ហើយគ្មានសំបក និងមានគុណភាពល្អសម្រាប់ធ្វើជាចំណីសត្វ។

**ដំណាំកសិ-ពាណិជ្ជកម្ម**
(Agro-Business Crops)
សំដៅដល់ដំណាំដែលដាំដុះសម្រាប់ការលក់ដូរយកប្រាក់ចំណេញ។

**ដំណាំប្រចាំសតវត្សរ៍ទី២១**
(21st Century Crops)
សំដៅដល់ដំណាំពហុប្រយោជន៍ដែលឆ្លើយតបនឹងតម្រូវការអាទិភាពរបស់ប្រទេសកំពុងអភិវឌ្ឍ និន្នាការសេដ្ឋកិច្ចសកល និងការប្រែប្រួលអាកាសធាតុ។

**ដំឡូងមី**
(Cassava)

សំដៅដល់ដំណាំមើមដែលស្តុកជាតិម្សៅម៉្យាង មានភាពធន់នឹងគ្រោះរាំងស្ងួត និងអាចលូតលាស់បានក្នុងដីមានជីជាតិតិច។ ម្សៅរបស់វាអាចយកផលិតជាផលិតផលជាច្រើនមុខឬលាយជាមួយសារធាតុដទៃទៀត ក្នុងអាហារ ឧស្សាហកម្ម ប្រេងឥន្ធនៈ។ វាចែកចេញជាពីរអំបូរ(ផ្អែមនិងចត់) មានដើមកំណើតនៅទ្វីបអាម៉េរិក និងសាយភាយចូលក្នុងបណ្តាប្រទេសផ្សេងៗក្នុងទ្វីបអាស៊ីនិងអាហ្វ្រិក។

**ប្រព័ន្ធសុខដុមនីយកម្ម**
Harmonized System (HS)

សំដៅដល់វិធីសាស្ត្រក្នុងការធ្វើចំណាត់ថ្នាក់ទំនិញក្នុងប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិដែលបង្កើតដោយអង្គការគយពិភពលោក។

**ប្រព័ន្ធអេកូឡូស៊ីកសិកម្ម**
(Agriculture Eco System)

សំដៅដល់បណ្តុំនៃរុក្ខជាតិ សត្វ និងមីក្រូសារពាង្គកាយដែលមានអន្តរប្រតិកម្មនឹងគ្នាក្នុងបរិស្ថានរូបវន្តនិងគីមីដែលបង្កើតដោយមនុស្ស ដើម្បីផលិតស្បៀងឬវត្ថុធាតុដើមផ្សេងៗសម្រាប់បំពេញតម្រូវការមនុស្សនិងការកែច្នៃ។

**ផលិតកម្មដំឡូងមីវៃឆ្លាត**
(Smart Cassava Production)

សំដៅដល់ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការដាំដុះដំឡូងមីឱ្យបានទិន្នផលខ្ពស់ បន្សាំនឹងការប្រែប្រួលអាកាសធាតុ ក្នុងគោលបំណងបង្កើនប្រាក់ចំណូលកសិករ និងធានាការផ្គត់ផ្គង់ផលិតផលដល់ទីផ្សារ។

**ផលិតកម្មបែបពាណិជ្ជកម្ម**
(Commercial Production)

សំដៅដល់ការដាំដុះដំណាំក្នុងគោលបំណងលក់ ដើម្បីទទួលបានប្រាក់ចំណូល។

**ផលិតកម្មផ្អែកលើទីផ្សារ**
(Market-Based Production)

សំដៅដល់ដំណើរការផលិតផលិតផលកសិកម្មឱ្យត្រូវនឹងទីផ្សារ ទាំងបរិមាណ គុណភាព និងតម្លៃ ដើម្បីកាត់បន្ថយហានិភ័យកើតចេញពីអតុល្យភាពរវាងការផ្គត់ផ្គង់និងតម្រូវការ។ តម្រូវការទីផ្សារត្រូវសិក្សាដើម្បីរៀបចំផែនការដាំដុះនិងប្រមូលផល។

**ពាណិជ្ជូបនីយកម្ម កសិកម្ម(ដំឡូងមី)**
(Cassava Agricultural Commercialization)

សំដៅដល់ដំណើរការមួយដែលវិស័យកសិកម្មមានអន្តរកម្មជាមួយវិស័យដទៃទៀតដែលមានក្នុងសេដ្ឋកិច្ច ហើយផលប៉ះពាល់របស់វាពឹងផ្អែកលើលក្ខខណ្ឌនៃវិស័យទាំងនេះ។

**ភាពជាដៃគូរវាងអ្នកផលិត**
(Producer Public Private Partnership)

សំដៅដល់វិស័យសាធារណៈនិងវិស័យឯកជន គឺជាយន្តការមួយដែលវិស័យសាធារណៈនិងឯកជនសហការគ្នាដើម្បីដោះស្រាយបញ្ហារាំងស្ទះដល់ដំណើរការរបស់ខ្សែច្រវាក់តម្លៃ។

**ភាពសុក្រឹតនៃកសិកម្ម**
(Precision Agricultural)

សំដៅដល់វិធីសាស្ត្រដើម្បីគ្រប់គ្រងការដាំដុះដោយប្រើប្រព័ន្ធព័ត៌មានបច្ចេកវិទ្យា ដើម្បីផ្តល់ឱ្យដីនិងដំណាំនូវអ្វីដែលវាត្រូវការ ដូចនេះអាចទទួលបានផលិតភាពខ្ពស់។

**ម្សៅដំឡូងមី**
(Cassava Starch)

សំដៅដល់ម្សៅដែលចម្រាញ់ចេញពីមើមដំឡូងមី។ ការចម្រាញ់នេះគឺធ្វើឡើងដោយប្រើទឹកដើម្បីបន្សាបជាតិពុលឬតាមរយៈការកិនចំណិតដំឡូងក្រៀមដែលហាលស្ងួត។

| | |
|---|---|
| **ម្សៅដំឡូងមីសរីរាង្គ** (Organic Cassava Starch) | សំដៅដល់ម្សៅដែលចម្រាញ់ចេញពីមើមដំឡូងមីសរីរាង្គ។ ដើម្បីទទួលបានជាម្សៅសរីរាង្គ ដំណើរការដាំដុះនិងកែច្នៃត្រូវអនុលោមតាមស្តង់ដាសរីរាង្គ ដែលកំណត់ដោយទីផ្សារបញ្ជាទិញនីមួយៗ។ |
| **លទ្ធភាពទទួលបានប្រាក់ចំណេញ** (Profitability) | សំដៅដល់លទ្ធភាពដែលអាចប្រើធនធានដែលមាន ដើម្បីបង្កើតចំណូលឱ្យច្រើនជាងចំណាយឱ្យកាន់តែច្រើនតាមតែអាចធ្វើទៅបាន។ |
| **សារធាតុស្យានីដអ៊ីដ្រូសែន** (HCN) (Hydrogen Cyanide) | សំដៅដល់សមាសភាគគីមីម៉្យាង ដែលគ្មានពណ៌ ហើយពុលនិងងាយឆេះ។ |
| **អេតាណុល** (Ethanol) | សំដៅដល់សារធាតុរាវ ថ្លា គ្មានពណ៌ គ្មានក្លិនម៉្យាង ដែលស្ថិតក្នុងប្រភេទអាល់កុលសម្រាប់ធ្វើជាចំហេះ ភេសជ្ជៈ ប្រេងឥន្ធនៈ ទឹកអប់។ល។ |
| **អ្នកទទួលយកថ្លៃ** (Price taker) | សំដៅដល់អ្នកដែលយកថ្លៃពីអ្នកដទៃធ្វើជាមូលដ្ឋាន ដើម្បីកំណត់ថ្លៃទិញលក់របស់ខ្លួន។ ជាទូទៅ ពួកគេមិនមានអំណាចចរចាឬគ្មានឥទ្ធិពលនៅក្នុងទីផ្សារ។ |
| **អ្នកផ្គត់ផ្គង់បំពេញបន្ថែម** (Marginal supplier) | សំដៅដល់អ្នកផ្គត់ផ្គង់ដែលទទួលបានការបញ្ជាទិញ នៅពេលដែលអតិថិជនខ្វះខាតឬមិនអាចបំពេញតម្រូវការទីផ្សារបាន។ |
| **ឧត្តមភាពប្រកួតប្រជែង** (Competitive Excellence) | សំដៅដល់សមត្ថភាពដែលក្រុមហ៊ុនមួយឬប្រតិបត្តិករមួយអាចធ្វើបានល្អ តម្លៃថោកជាង និងមានប្រសិទ្ធភាពជាងអ្នកលក់ឬអ្នកផ្គត់ផ្គង់ដទៃទៀត។ |

## ឧបសម្ព័ន្ធទី១ : សកម្មភាពលម្អិតសម្រាប់អនុវត្តគោលនយោបាយជាតិដំឡូងមី

ដំណាក់កាលទី១ - រយៈពេលខ្លី ( ១-២ឆ្នាំ ) : *ផលិតភាពនៃផលិតកម្មដំឡូងមីនៅកម្ពុជា ត្រូវបានបង្កើនតាមរយៈការបង្កើនទិន្នផលនិងការកាត់បន្ថយថ្លៃដើមផលិតកម្ម ដោយគ្មានហានិភ័យដល់ប្រព័ន្ធអេកូឡូស៊ីកសិកម្ម*

| រយៈពេលខ្លី | បញ្ហានានាដែលត្រូវដោះស្រាយ | មូលហេតុ | សកម្មភាព | ស្ថាប័នដែលទទួលខុសត្រូវ |
|---|---|---|---|---|
| ការលើកកម្ពស់ផលិតភាពផលិតកម្មនៅចម្ការដំឡូងមីដើម្បីបង្កើនប្រាក់ចំណូលដល់កសិករ ដោះស្រាយបញ្ហាធ្លាក់ថ្លៃ និងរក្សាភាពប្រកួតប្រជែងផលិតកម្មរបស់កម្ពុជា | ទិន្នផលថយចុះ | ដីជាតិដីនៅតំបន់ភាគច្រើន មិនត្រូវបានធ្វើការវិភាគ ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងជំរុញប្រើប្រាស់ឱ្យបានត្រឹមត្រូវតាមគោលការណ៍វិទ្យាសាស្ត្រ | ១.១.១. សិក្សាវាយតម្លៃភាពសមស្របនៃដីចំពោះដំណាំដំឡូងមី ធ្វើផែនការប្រើប្រាស់ និងកំណត់តំបន់ដាំដុះឱ្យបានច្បាស់លាស់ ព្រមទាំងតាមដាននៃការវិវឌ្ឍទិន្នផលរបស់កសិករ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | | ១.១.២. កំណត់និងជំរុញផលិតកម្មដំឡូងមីនៅតំបន់ដែលមានលក្ខណៈសមស្របឱ្យអនុលោមតាមគោលការណ៍និរន្តរភាពនិងការអនុវត្តកសិកម្មល្អ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | ចំណេះដឹងទាក់ទងនឹងការអនុវត្តផ្នែកក្សេត្រសាស្ត្រចំពោះដំណាំដំឡូងមីនៅមានកម្រិត | ១.១.៣. ប្រមូលនិងចងក្រងឯកសារទាក់ទងនឹងការអនុវត្តផ្នែកក្សេត្រសាស្ត្រដែលមានក្នុងប្រទេសកម្ពុជានិងតំបន់ និងវាយតម្លៃជ្រើសរើសយកបច្ចេកទេសសមស្របនិងមានប្រសិទ្ធភាព | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | | ១.១.៤. ធ្វើពិសោធន៍ការអនុវត្តផ្នែកក្សេត្រសាស្ត្រ និងផ្សព្វផ្សាយទៅកាន់កសិករ តាមរយៈប្រព័ន្ធផ្សព្វផ្សាយបច្ចេកទេសកសិកម្មដែលមានប្រសិទ្ធភាពដល់កសិករ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងព័ត៌មាន |
| | | | ១.១.៥. ធ្វើការបណ្តុះបណ្តាលដល់មន្ត្រី | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | | | | |
|---|---|---|---|---|
| | | | ផ្សព្វផ្សាយបច្ចេកទេសកសិកម្មនិងភ្នាក់ងារមូលដ្ឋាន ចំពោះការអនុវត្តក្បេត្រសាស្ត្រត្រឹមត្រូវ និងការគ្រប់គ្រងដីប្រកបដោយប្រសិទ្ធភាព ទាក់ទងនឹងផលិតកម្មដំឡូងមី | |
| | | | ១.១.៦. ផ្តល់សិទ្ធិអនុញ្ញាតឱ្យតែមន្ត្រី/ភ្នាក់ងារមូលដ្ឋានដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវនិងមានវិជ្ជាជីវៈដើម្បីផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មទៅដល់កសិករ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | | ១.១.៧. រៀបចំផែនការដាំដុះដំឡូងមី វិភាគថ្លៃផលិតកម្ម និងត្រួតពិនិត្យការអនុវត្តក្បេត្រសាស្ត្រនៅតំបន់ដាំដុះដំឡូងមី និងធ្វើបច្ចុប្បន្នភាពទៀងទាត់ ដើម្បីធានាភាពត្រឹមត្រូវនៃទិន្នន័យកសិកម្ម និងប្រសិទ្ធភាពការងារ។ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | ពូជដំឡូងមីមិនត្រូវបានវិភាគ និងជំរុញឱ្យដាំដុះដោយផ្អែកលើកត្តាដី អាកាសធាតុ សណ្ឋានដី ទីតាំងភូមិសាស្ត្រ និងតម្រូវការរបស់រោងចក្រឧស្សាហកម្ម ។ល។ | ១.១.៨. កំណត់ពូជដំឡូងមីដែលបានដាំដុះក្នុងប្រទេសកម្ពុជា និងតាមដានលើទិន្នផល ភាពធន់នឹងជំងឺ ភាពធន់នឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងគុណភាពនិងបរិមាណម្សៅ និងត្រូវធ្វើការប្រមូលទុកដាក់ពូជដំឡូងមី ជាពិសេសប្រភេទដែលអាចហូបបានផ្ទាល់ ដើម្បីបម្រើការងារសិក្សាស្រាវជ្រាវកែច្នៃជាផលិតផលអាហារ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | | ១.១.៩. ជំរុញនិងគាំទ្រកសិដ្ឋាន បណ្តុះពូជ និងផ្គត់ផ្គង់ដើមដំឡូងមីឯកជន ដើម្បីលក់និងចែកចាយដើមដែលមានសុខភាពល្អ/គ្មានមេរោគដល់កសិករ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសាកលវិទ្យាល័យ |
| | | | ១.១.១០. ជ្រើសរើសនិងនាំចូលពូជដំឡូងមី | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | | | | |
|---|---|---|---|---|
| | | | ដែលមានលក្ខណៈសម្បត្តិល្អនិងសមស្របនឹងស្ថានភាពចម្ការរបស់កសិករនិងតម្រូវការរបស់រោងចក្រឧស្សាហកម្មកែច្នៃ | |
| | | | ១.១.១១. ត្រួតពិនិត្យគុណភាពនិងគ្រប់គ្រងហានិភ័យដែលអាចកើតមានឡើងពីការនាំចូលពូជនិងដើមដំឡូងមីពីប្រទេសជិតខាងនិងផ្សេងៗទៀតចូលមកកម្ពុជា | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | ការកើតឡើងនៃសមាសភាពចង្រៃនិងជំងឺ ធ្វើឱ្យប៉ះពាល់ដល់ផលិតភាពផលិតកម្មដំឡូងមីនៅតំបន់មួយចំនួន( ទិន្នផលថយចុះ ឬបាត់បង់ទាំងស្រុង) | ១.១.១២. ត្រួតពិនិត្យ ស្វែងរកប្រភព និងតាមដានសមាសភាពចង្រៃ ជំងឺ និងកត្តាអាក្រក់ទាំងឡាយដែលកំពុងបង្កផលប៉ះពាល់អវិជ្ជមានដល់ផលិតកម្មដំឡូងមី ព្រមទាំងទប់ស្កាត់ការរីករាលដាល | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | | ១.១.១៣. ធ្វើការឃ្លាំមើលនិងបង្កើតយន្តការបង្ការទប់ស្កាត់ដើម្បីគ្រប់គ្រងនិងកាត់បន្ថយហានិភ័យពីសមាសភាពចង្រៃទាំងនោះ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | | ១.១.១៤. ធ្វើបច្ចុប្បន្នភាព និងបង្កើតក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិដែលចាំបាច់ ដើម្បីទប់ស្កាត់ បង្ការ បង្ក្រាប និងធ្វើអន្តរាគមន៍ទាន់ពេលចំពោះប្រភព ភ្នាក់ងារ និងកាតាលីករដែលនាំឱ្យមានការកកើតនិងរីករាលដាលនៃសមាសភាពចង្រៃ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | គុណភាពនៃធាតុចូលកសិកម្មមិនអាចទុកចិត្តបាន ដូចជាជី ថ្នាំ ជាដើម | ១.១.១៥. វាយតម្លៃគុណភាពធាតុចូលកសិកម្មដែលបានប្រើប្រាស់សម្រាប់ដំឡូងមី និងហាមឃាត់នូវធាតុចូលទាំងឡាយណាដែលមិនបំពេញតាមស្តង់ដាគុណភាព | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | | ១.១.១៦. ធ្វើការបណ្តុះបណ្តាលអ្នកផ្គត់ផ្គង់ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | | | | |
|---|---|---|---|---|
| | | | ធាតុចូលកសិកម្ម ដើម្បីប្រែក្លាយពួកគេជាភ្នាក់ងារមានវិជ្ជាជីវៈ ដែលអាចណែនាំកសិករឱ្យប្រើប្រាស់ធាតុចូលកសិកម្មបានត្រឹមត្រូវ ប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព | |
| | | | ១.១.១៧. កំណត់ឱ្យមានសេចក្តីណែនាំសង្ខេបពីការប្រើប្រាស់ធាតុចូលកសិកម្មជាភាសាខ្មែរ និងមានលេខទំនាក់ទំនងសម្រាប់សាកសួរព័ត៌មានបន្ថែមលើផលិតផលធាតុចូលកសិកម្ម | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | បម្រែបម្រួលអាកាសធាតុធ្វើឱ្យប៉ះពាល់ដល់ការរស់រាន ការលូតលាស់ និងផលិតភាពនៃដើមដំឡូងមី ព្រមទាំងបង្កើតនូវចំណាយបន្ថែមលើការដាំដុះ | ១.១.១៨. កំណត់ទីតាំងឬតំបន់ដែលរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ ធ្វើការវិភាគ និងវាយតម្លៃពីផលប៉ះពាល់ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | | ១.១.១៩. បង្កើតផែនការបន្សាំ និងកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុសម្រាប់ទីតាំងឬតំបន់ដំឡូងមីដែលងាយរងគ្រោះនិងរងផលប៉ះពាល់ ព្រមទាំងកំណត់សក្តានុពលពិពិធកម្មដំណាំកសិកម្មនៅតំបន់ដាំដុះដំណាំដំឡូងមី | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងបរិស្ថាន |
| | | | ១.១.២០. កសាងហេដ្ឋារចនាសម្ព័ន្ធដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | ការដាំដុះដំឡូងមី ពឹងផ្អែកលើធម្មជាតិឬយថាផល ដោយសារតែកង្វះប្រព័ន្ធធារាសាស្ត្រ | ១.១.២១. ធ្វើការស្រាវជ្រាវអំពីប្រព័ន្ធធារាសាស្ត្រខ្នាតតូចដែលមានតម្លៃថោកនិងមានប្រសិទ្ធភាពសម្រាប់ផលិតកម្មដំឡូងមី | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | | ១.១.២២. ពិសោធនិងសាកល្បងប្រព័ន្ធ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | | | | |
|---|---|---|---|---|
| | | | ជាពសាស្ត្រខ្នាតតូច ដែលបានច្នៃប្រឌិតសម្រាប់ចម្ការដំឡូងមី និងផ្សព្វផ្សាយដល់កសិករ | |
| | | | ១.១.២៣. បង្កើតគម្រោងគាំទ្រ និងផ្តល់ឥណទានដល់កសិករដើម្បីវិនិយោគលើប្រព័ន្ធជាពសាស្ត្រខ្នាតតូចសម្រាប់ការដាំដុះដំឡូងមីពេញមួយឆ្នាំ និងដាំដុះដោយបត់បែនផ្អែកលើតម្រូវការរបស់ទីផ្សារ | ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម |
| | ការកើនឡើងនៃចំណាយផលិតកម្មដំឡូងមី | ថ្លៃធាតុចូលកសិកម្មកើនឡើងក្នុងអំឡុងពេលដែលមានតម្រូវការប្រើប្រាស់(នៅពេលដែលធាតុចូលកសិកម្មទាំងនោះចាំបាច់ត្រូវប្រើប្រាស់) | ១.១.២៤. បង្កើតគម្រោងកម្ចីហិរញ្ញវត្ថុពិសេសដែលកសិករអាចទិញធាតុចូលកសិកម្មទុកជាមុន | ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម |
| | | ចម្ការដំឡូងមីរបស់ប្រជាកសិករកម្ពុជាភាគច្រើនមានទំហំតូច ដែលគ្មានវិមាត្រសេដ្ឋកិច្ចនិងផ្តល់ផលចំណេញច្រើនគ្រប់គ្រាន់សម្រាប់បង្កើនសុខុមាលភាពគ្រួសារ | ១.១.២៥. បង្កើតយន្តការប្រើប្រាស់ដីសមូហភាពដើម្បីកាត់បន្ថយថ្លៃដើមផលិតកម្ម និងបង្កើនការប្រើប្រាស់មធ្យោបាយផលិតកម្មរួមគ្នា តាមរយៈការជួលឬផ្តល់សេវាឱ្យគ្នាទៅវិញទៅមក | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | | | ១.១.២៦. ជួយកសិករដែលមានឆន្ទៈដើម្បីពង្រីកផ្ទៃដីដាំដុះ តាមរយៈគម្រោងជួលដីដែលមានការធានា (ជៀសវាងជម្លោះដីធ្លី) | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | ថ្លៃឈ្នួលសេវាកម្មកសិកម្មឯកជនមិនត្រូវបានវិភាគ និងមានវិធានការសមស្របដើម្បីបង្កើនផលប្រយោជន៍ដល់អ្នកផ្តល់សេវានិងកសិករ | ១.១.២៧. វិភាគកត្តាដែលកំពុងប៉ះពាល់ដល់ថ្លៃសេវាកម្មកសិកម្ម (ប្រៀបធៀបរវាងសេវាកម្មបុគ្គលនិងសេវាពាណិជ្ជកម្ម) | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | | ១.១.២៨. ចងក្រងអ្នកផ្តល់សេវាកម្មកសិកម្ម | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | | | | |
|---|---|---|---|---|
| | | | ជាក្រុម ឬជាសហគមន៍ | |
| | | | ១.១.២៩. ផ្តល់ការបណ្តុះបណ្តាលដល់សហគមន៍សេវាកម្មកសិកម្ម ដើម្បីបង្កើនផលិតភាពនិងលើកកម្ពស់គុណភាពសេវាកម្មរបស់ពួកគេដែលផ្តល់ដល់កសិករ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | | ១.១.៣០. បង្កើតប្រព័ន្ធអេឡិចត្រូនិក ដែលអាចឱ្យកសិករនិងអ្នកផ្តល់សេវាកម្មចរចានិងព្រមព្រៀងលើការផ្តល់និងទទួលយកសេវាកសិកម្មផ្អែកលើការផែនការផលិតកម្មជំឡុងមី | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, វិស័យឯកជន |
| | ការបាត់បង់ពេលប្រមូលផលនិងក្រោយប្រមូលផលជាបញ្ហាដែលមិនត្រូវបានយកចិត្តទុកដាក់នាពេលកន្លងមក | ការបាត់បង់ពេលប្រមូលផលនិងក្រោយពេលប្រមូលផលបណ្តាលមកពីកត្តាមនុស្ស ធម្មជាតិ និងកត្តាពាក់ព័ន្ធដទៃទៀត។ កត្តាទាំងនេះមិនត្រូវបានធ្វើការវិភាគនិងយកចិត្តទុកដាក់។ | ១.១.៣១. សិក្សាពីការបាត់បង់ពេលប្រមូលផលនិងក្រោយប្រមូលផលលើជំឡុងមី និងធ្វើបច្ចុប្បន្នភាពនៅពេលដែលមានភាពចាំបាច់ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| | | | ១.១.៣២. បណ្តុះបណ្តាលកសិករនិងតួអង្គពាក់ព័ន្ធក្នុងខ្សែចង្វាក់តម្លៃ ដើម្បីអនុវត្តវិធានការមានប្រសិទ្ធភាព ដើម្បីគ្រប់គ្រងនិងកាត់បន្ថយការបាត់បង់ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | | ១.១.៣៣. បង្កើតឱ្យមាននូវហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ដែលអាចឱ្យកសិករប្រើប្រាស់ឬជួល ដើម្បីគ្រប់គ្រងការបាត់បង់ការប្រមូលផល រក្សាទុកផលិតផលនិងកែច្នៃបឋម ដើម្បីរក្សាគុណភាពនិងលក់ផលិតផលក្នុងពេលសមស្រប | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម |
| | | ជំនាញគ្រប់គ្រងកសិកម្មមិនត្រូវបានណែនាំ និងគ្មានការគាំទ្រជាប្រព័ន្ធដើម្បីបណ្តុះបណ្តាលកសិករ | ១.១.៣៤. ធ្វើការបណ្តុះបណ្តាលដល់កសិករ ជាពិសេសប្រធានអង្គការកសិករ ស្តីពីសហគ្រិនភាពផ្នែកកសិកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុ | ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម |
| | | | ១.១.៣៥. ជំរុញគម្រោងសន្សំប្រាក់ និងសហជីព | ធនាគារជាតិនៃកម្ពុជា, |

| | | | ឥណទាននៅកម្រិតសហគមន៍ | ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម |
|---|---|---|---|---|
| លើកកម្ពស់កិច្ចសហការខ្សែចង្វាក់តម្លៃក្នុងតំបន់ដើម្បីបង្កើតនិងផ្តល់អត្ថប្រយោជន៍ទៅវិញទៅមក ( កម្ពុជានិងប្រទេសជិតខាង ) | ការនាំចេញចំណិតដំឡូងមីទៅកាន់ប្រទេសជិតខាងត្រូវរាំងស្ទះដោយការគាំពារនិយម និងរបាំងបច្ចេកទេសពាណិជ្ជកម្មនាពេលកន្លងមក | គុណភាពនៃចំណិតដំឡូងមីមិនបំពេញបាននូវបទដ្ឋានបច្ចេកទេសនិងតាមស្តង់ដាជាតិ | ១.១.៣៦. បណ្តុះបណ្តាលកសិករលើការគ្រប់គ្រងគុណភាពផលិតផល | ក្រសួងពាណិជ្ជកម្ម |
| | | | ១.១.៣៧. ច្នៃប្រឌិតនិងបង្កើតម៉ាស៊ីនតូច ដើម្បីផលិតចំណិតដំឡូងមីជំនួសឱ្យការកាប់ដោយដៃដែលសមស្របសម្រាប់ការប្រើប្រាស់ជាលក្ខណៈគ្រួសារនិងសហគមន៍ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងពាណិជ្ជកម្ម |
| | | | ១.១.៣៨. បង្កើតឱ្យមានឧបករណ៍សម្ងួតចល័តខ្នាតតូច សម្រាប់ការសម្ងួតចំណិតដំឡូងមី | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងពាណិជ្ជកម្ម |
| | | | ១.១.៣៩. បង្កើតនិងធ្វើបច្ចុប្បន្នភាពស្តង់ដាផលិតផលនិងបទដ្ឋានបច្ចេកទេស និងត្រួតពិនិត្យភាពអនុលោមរបស់អ្នកកែច្នៃនិងពាណិជ្ជករ ស្របពេលនឹងការលើកកម្ពស់បច្ចេកទេសក្រោយពេលប្រមូលផល រួមទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធសម្ងួតទុកដាក់និងកែច្នៃផលិតផលនិងលើកទឹកចិត្តការកែច្នៃវត្ថុធាតុដើមនិងកែច្នៃផលិតផលសម្រេចនៅក្នុងស្រុក | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងពាណិជ្ជកម្ម |
| | | បាតុភូតរដូវនិងភាពអសកម្មដែលផ្តល់ផលអវិជ្ជមានដល់កសិករកម្ពុជា | ១.១.៤០. ត្រូវមានមូលនិធិគាំទ្រពិសេស ដើម្បីធ្វើអន្តរាគមន៍ក្នុងអំឡុងពេលមានដំឡូងជន់ បិទព្រំដែន ក្នុងពេលដែលប្រទេសជិតខាងប្រមូលផលនិងការអេក់អេួលទីផ្សារ( ចូលឆ្នាំចិន ) ព្រមទាំងជំរុញយន្តការធានារ៉ាប់រងនៃការដាំដុះដំឡូងមី "Crop Insurance" | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម |

| | | | | |
|---|---|---|---|---|
| ជំរុញការនាំចេញផលិតផលកែច្នៃដើម្បីបង្កើតតម្លៃបន្ថែមនិងធានាសុវត្ថិភាពទីផ្សារសម្រាប់កសិករកម្ពុជា | រដូវប្រមូលផលដំឡូងមីមានរយៈពេលខ្លីដែលត្រឹមតែ ៤ខែ ទៅ ៥ខែ | ការប្រកួតប្រជែងដណ្តើមដំឡូងមីមាន លក្ខណៈខ្លាំងក្លាក្នុងអំឡុងពេលរដូវប្រមូលផល ដែលគំរាមកំហែងដល់ដំណើរការរបស់ឧស្សាហកម្មកែច្នៃដំឡូងមីក្នុងស្រុក (ម្សៅដំឡូងមី, អេតាណុល) | ១.១.៤១. ជំរុញផលិតកម្មកសិកម្មតាមកិច្ចសន្យារវាងកសិករនិងអ្នកកែច្នៃ ដើម្បីកសាងទំនុកចិត្តនិងផ្តល់ផលប្រយោជន៍ដល់គ្នាទៅវិញទៅមក | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | រោងចក្រឧស្សាហកម្មកែច្នៃដំឡូងមីកម្ពុជាមិនទាន់ដំណើរការល្អ និងឈានទៅដល់កម្រិតប្រកួតប្រជែង | ការទទួលបានហិរញ្ញវត្ថុនៅមានកម្រិត ដោយសារតែពួកគេមិនមានទ្រព្យបញ្ចាំគ្រប់គ្រាន់ និងមានប្រព័ន្ធអភិបាលកិច្ចក្រុមហ៊ុនខ្សោយ | ១.១.៤២. អភិវឌ្ឍជំនាញសហគ្រិនភាពនិងផ្តល់ការគាំទ្របច្ចេកទេសដើម្បីរៀបចំប្រព័ន្ធអភិបាលកិច្ចក្រុមហ៊ុន សម្រាប់ការទទួលបានកម្ចីហិរញ្ញវត្ថុសមស្រប (Impact investors) | ធនាគារជាតិនៃកម្ពុជា,<br>ក្រសួងពាណិជ្ជកម្ម,<br>ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម |
| | រោងចក្រឧស្សាហកម្មកែច្នៃមិនអាចបង្កើតតម្លៃបន្ថែមច្រើនពីការកែច្នៃនិងកាកសំណល់ | ដោយសារតែហិរញ្ញវត្ថុមានកម្រិត ពួកគេមិនមានលទ្ធភាពទាញយកអត្ថប្រយោជន៍ពីបច្ចេកវិជ្ជាទំនើបដើម្បីកាត់បន្ថយថ្លៃចំណាយ និងបង្កើតតម្លៃបន្ថែមទៀតពីកាកសំណល់(កាកសំណល់រឹង និងរាវ) | ១.១.៤៣. បង្កើតមូលនិធិកម្ចីពិសេស ដើម្បីជួយអ្នកកែច្នៃម្សៅដំឡូងមីក្នុងស្រុក តាមរយៈការអភិវឌ្ឍរោងចក្រឱ្យកាន់តែទំនើប និងបង្កើនបរិមាណផលិតផលកែច្នៃ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,<br>ធនាគារជាតិនៃកម្ពុជា,<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| | | | ១.១.៤៤. ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់អ្នកកែច្នៃម្សៅដំឡូងមីក្នុងស្រុក ដើម្បីទទួលបង្កើតតម្លៃបន្ថែមនិងកាត់បន្ថយថ្លៃដើមផលិតកម្ម | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍,<br>ក្រសួងពាណិជ្ជកម្ម |
| | សម្រាប់រោងចក្រកែច្នៃដំឡូងមី ថ្លៃលក់អគ្គិសនីត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ពី២១សេនដុល្លារអាមេរិកនៅឆ្នាំ២០១៤ មក១៤.៧សេនដុល្លារអាមេរិកនៅឆ្នាំ២០១៩ ប៉ុន្តែនៅខ្ពស់ជាងប្រទេសជិតខាង | ថ្លៃអគ្គិសនីជាផ្នែកមួយនៃការចំណាយថ្លៃដើមផលិតកម្មរោងចក្រកែច្នៃដំឡូងមី | ១.១.៤៥. អនុវត្តផែនការយុទ្ធសាស្ត្របន្ថយអត្រា និងតម្លាភាពថ្លៃលក់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទទូទាំងប្រទេសសម្រាប់ឆ្នាំ២០១៩និង២០២០ ដែលក្នុងនោះមានឧស្សាហកម្មកែច្នៃដំឡូងមីផងដែរ | ក្រសួងរ៉ែនិងថាមពល, |
| | | | ១.១.៤៦. ពង្រីកវិសាលភាពផ្គត់ផ្គង់អគ្គិសនីនិងស្ថិរភាពជូនដល់អ្នកប្រើប្រាស់គ្រប់ប្រភេទ ក៏ដូចជាជូនដល់ឧស្សាហកម្មកែច្នៃដំឡូងមីផងដែរ។ | ក្រសួងរ៉ែនិងថាមពល, |

| | | | | |
|---|---|---|---|---|
| | | | ១.១.៤៧. ផ្តល់ព័ត៌មានដល់អ្នកប្រើប្រាស់គ្រប់ប្រភេទ ប្រសិនជាមានផែនការផ្តាច់ចរន្ត ដើម្បីផ្ទុសផុល ដំឡើង និងថែទាំ | ក្រសួងរ៉ែនិងថាមពល |
| | ការជ្រៀតចូលទីផ្សារ ការស្រាវជ្រាវ និងនវានុវត្តភាពនៅមានកម្រិត | អ្នកកែច្នៃម្សៅដំឡូងមីភាគច្រើនសមត្ថភាពមានកម្រិតក្នុងការស្វែងរកព័ត៌មានទីផ្សារ រៀបចំផែនការ ធ្វើទំនើបកម្មរោងចក្រ ព្រមទាំងអភិវឌ្ឍន៍ផលិតផលថ្មីៗ | ១.១.៤៨. វិភាជន៍ថវិកាសម្រាប់ការសិក្សាស្រាវជ្រាវទីផ្សារ បច្ចេកវិជ្ជា និងអភិវឌ្ឍន៍ផលិតផលពីដំឡូងមី | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| | | | ១.១.៤៩. បង្កើតឱ្យមានបណ្តាញទំនាក់ទំនង ឬធុរកិច្ចសម្រាប់អ្នកកែច្នៃក្នុងស្រុក ដើម្បីទទួលបានចំណេះដឹងពីបច្ចេកវិជ្ជា ជំនាញការ និងក្រុមហ៊ុនម៉ាឃីតជីង ឬអ្នកផ្តល់សេវាកម្មផ្សេងៗ | ក្រសួងពាណិជ្ជកម្ម |
| | របាំងនៃការដឹកជញ្ជូនឆ្លងកាត់ប្រទេសជិតខាងមានការលំបាក | នីតិវិធីនៃការដឹកទំនិញឆ្លងកាត់ប្រទេសជិតខាងមិនច្បាស់លាស់ និងប្រែប្រួលមិនទៀងទាត់ | ១.១.៥០. ពិភាក្សានិងចរចាជាមួយប្រទេសជិតខាង ដើម្បីបង្កើតនីតិវិធីច្បាស់លាស់សម្រាប់ការនាំចេញទំនិញឆ្លងកាត់និងតាមកំពង់ផែរបស់ប្រទេសជិតខាង | ក្រសួងសាធារណការនិងដឹកជញ្ជូន |
| | ថ្លៃចំណាយផ្សេងៗទាក់ទងនឹងការដំណើរការអាជីវកម្ម បង្កើនថ្លៃផលិតផល | ពន្ធផ្សេងៗបង្កើនថ្លៃដើមផលិតកម្ម ដូចជាៈប្រភេទពន្ធមួយចំនួនត្រូវដកចេញឬកាត់បន្ថយ | ១.១.៥១. កាត់បន្ថយឬលើកលែងពន្ធមួយចំនួន ដើម្បីឱ្យតម្លៃផលិតផលធ្លាក់ចុះ និងបង្កើនប្រាក់ចំណេញដល់រោងចក្រកែច្នៃ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| | ការធ្វើអាជីវកម្មពាណិជ្ជកម្មមិនត្រឹមត្រូវ ការក្លែងបន្លំគុណភាព | ការប្រកួតប្រជែងមិនស្មោះត្រង់ ធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និងរាំងស្ទះដល់បណ្តាអាជីវករ-ពាណិជ្ជករមានក្រមសីលធម៌ និងមានឆន្ទៈអនុវត្តច្បាប់ ជាពិសេសគោលនយោបាយជាតិដំឡូងមី | ១.១.៥២. ត្រួតពិនិត្យនិងតាមដានការធ្វើអាជីវកម្មពាណិជ្ជកម្មនៅតាមព្រំដែនដែលរំលោភច្បាប់ និង/ឬសកម្មភាពទាំងឡាយណាដែលធ្វើឱ្យខូចកេរ្តិ៍ឈ្មោះប្រទេសកម្ពុជានិងរាជរដ្ឋាភិបាលនៅក្នុងទីផ្សារដំឡូងមី | ក្រសួងពាណិជ្ជកម្ម, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងមហាផ្ទៃ, ស្ថាប័នពាក់ព័ន្ធថ្នាក់ក្រោមជាតិ |

| | | | | |
|---|---|---|---|---|
| | ចំណាយរដ្ឋបាលក្រៅផ្លូវការត្រូវបានប្រមូលតាមចំណុចផ្សេងៗគ្នានៅក្នុងខ្សែចង្វាក់តម្លៃដំឡូងមី | កម្រៃក្រៅផ្លូវការទាំងនោះបង្កើតឱ្យមានការចំណាយបន្ថែម ដែលធ្វើឱ្យកាត់បន្ថយនូវប្រាក់ចំណេញរបស់កសិករ និងបង្កើនតម្លៃផលិតផល | ១.១.៥៣. ធ្វើការស៊ើបអង្កេត ត្រួតពិនិត្យ និងទប់ស្កាត់ភាពមិនប្រក្រតីដែលកើតមានឡើងក្នុងខ្សែចង្វាក់តម្លៃទាំងមូល | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងពាណិជ្ជកម្ម, ក្រសួងមហាផ្ទៃ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | កិច្ចសម្រួលពាណិជ្ជកម្មមិនទាន់អភិវឌ្ឍបានល្អស្របតាមប្រព័ន្ធពាណិជ្ជកម្មដំឡូងមី | ឯកសារតម្រូវសម្រាប់ការនាំចេញមានច្រើន ដូច្នេះ វាបង្កើនចំណាយ និងទាមទារពេលវេលាច្រើនដើម្បីទទួលបានឯកសារពីស្ថាប័នទាំងនេះ | ១.១.៥៤. បង្កើតការិយាល័យច្រកចេញចូលតែមួយនៅតំបន់ពាណិជ្ជកម្មនិងទីតាំងនាំចេញសំខាន់ៗ ដើម្បីកាត់បន្ថយចំណាយនិងពេលវេលាសម្រាប់ការទទួលបានឯកសារពាណិជ្ជកម្ម | ក្រសួងពាក់ព័ន្ធ, រដ្ឋបាលថ្នាក់ក្រោមជាតិ, និងស្ថាប័នពាក់ព័ន្ធ |
| | | | ១.១.៥៥. បង្កើតឱ្យមានលក្ខណៈស្របគ្នា ដែលអាចធ្វើឱ្យការស្នើសុំ(ឯកសារនាំចេញ)នានាដំណើរការជាមុនបាន និងជានាភាពទុកចិត្តបាននៃសេវាកម្ម | ក្រសួងពាណិជ្ជកម្ម |
| | | | ១.១.៥៦. កំណត់ទីផ្សារថ្មីៗ និងធ្វើការចរចាជាមួយប្រទេសគោលដៅ ដើម្បីកំណត់និងរៀបចំកិច្ចសម្រួលពាណិជ្ជកម្មឱ្យបានរលូន។ ឯកសារមិនចាំបាច់សម្រាប់ការនាំចេញត្រូវដកចេញ។ | ក្រសួងពាណិជ្ជកម្ម |

